Formation, Dialogue, Cooperation

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែកុម្ភៈ ឆ្នាំទី៤ ថ្ងៃទី០១-២៨ ខែកុម្ភៈ ឆ្នាំ២០១១ លក់តម្លៃ ១000រៀល តែប៉ុណ្ណោះ លេខ ៤២

## មាតិកា



បុណ្យនៃក្តីស្រលាញ់... ទំព័រ ៥



ល្បុក្កតោក្បាច់គុណបុរាណ.. ទំព័រ ៩



សិល្បៈធ្វើក្រចក កំពុងពេញនិយម ទំព័រ ១៧

# អ្នកជំនាញ : "អាជីវកម្មខ្នាតតូចប្រភពការងារដ៏សំខាន់សម្រាប់ពលរដ្ឋក្រីក្រ"



ទោះបីមើលពីខាងក្រៅជារបរទទួលទានតូច តែវាបានរួមចំណែកយ៉ាងធំធេងក្នុងជីវភាពរស់នៅរបស់ប្រជាជន។ អាជីវកម្មខ្នាតតូចបានចូលរួមចំណែកយ៉ាងធំធេងក្នុងសេដ្ឋកិច្ចកម្ពុជា ដោយវាបានជួយឱ្យប្រជាជនក្រីក្រអាចរកចំណូលចិញ្ចឹមជីវិត ដោយមិនចំណាយដើមទុនច្រើន។ តើអ្វីជាអាជីវកម្មខ្នាតតូច? តើវាផ្តល់ប្រយោជន៍ និងកំពុងជួបការប្រឈមអ្វីខ្លះ? ទំព័រទី១០_១១

កម្មវិធី **ពន្លកថ្មី** ជាកម្មវិធីវិទ្យុថ្មីមួយរបស់
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកខ
កម្មវិធីនេះផ្តោតលើពលកម្មកុមារ និងបង្ការការកេងប្រវ័ញ្ច
លើកុមារ ដែលសហការជាមួយវិទ្យុសម្លេងប្រជាធិបតេយ្យ
VOD មានផ្សាយនៅរាល់ ថ្ងៃច័ន្ទ ម៉ោង ៤_៥ រសៀល
ផ្សាយនៅ FM 106.5 MHz ។

កម្មវិធីវិទ្យុ



**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : FM 102.5 Mhz ម៉ោង២:00-៣:00 រាល់រសៀលថ្ងៃសុក្រ
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:00-១១:00 រាល់ថ្ងៃសៅរ៍
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:00 យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 107.5 Mhz ម៉ោង៥:00-៦:00 រសៀលថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:00-៦:00 រសៀលថ្ងៃសៅរ៍

# រូបថតប្រចាំខែ




Photo : S. Philong

ឌីវីឌី-វីស៊ីឌី អាសអាភាស និងគ្មានទិដ្ឋាការ ព្រមទាំងម៉ាស៊ីនថតចម្លងថាសខុសច្បាប់ត្រូវក្រសួងវប្បធម៌ និងនគរបាលជាតិកម្ទេចចោល នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ នេះ។



Photo : Philong

យុវជនពេជ្រ ផល្លា អាយុ២០ឆ្នាំ និស្សិតនៅឆ្នាំទី១ ផ្នែកអក្សរសាស្ត្រអង់គ្លេសនៅសកលវិទ្យាល័យបៀលប្រាយ កំពុងឆ្លងកាត់ស្ពានមិត្តភាពកម្ពុជាជប៉ុនជ្រោយចង្វា។ យុវជនជាច្រើនកំពុងតស៊ូស្វែងរកអនាគតនៅទីក្រុងភ្នំពេញ។



Photo : Philong

អគ្គីភ័យជាច្រើនបានឆាបឆេះនាខែមករានៅរាជធានីភ្នំពេញ។ នេះជាអគ្គីភ័យនៅផ្សារអូរឫស្សីរាជធានីភ្នំពេញដែលបំផ្លាញផ្ទះមួយខ្នង។



Photo : Philong

អគ្គីភ័យដ៏ខ្លាំងក្លាកើតនៅគីឡូម៉ែត្រលេខ៧ សង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលបំផ្លាញផ្ទះជាង ៦០ខ្នង។



Photo : S. Philong

លំនៅដ្ឋាន ១២ខ្នង នៅសង្កាត់ទួលសង្កែ រាជធានីភ្នំពេញ ត្រូវអគ្គីភ័យឆាបឆេះកាលពីថ្ងៃទី២៤ មករា ឆ្នាំ២០១១

# វិចារណកថា

## ទទួលយកវប្បធម៌ថ្មីដោយមានព្រំដែនត្រឹមត្រូវ



លោកលី សុវណ្ណា ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក (CSC)

ការរស់នៅ ការប្រកបរបរចិញ្ចឹមជីវិត ការទទួលនូវការអប់រំដោយត្រឹមត្រូវ ការជ្រើសរើស និងការទទួល ជាសិទ្ធិរបស់បុគ្គលម្នាក់ៗ តែសិទ្ធិទាំងនោះ គឺស្ថិតនៅក្នុងក្របខណ្ឌនៃច្បាប់ និងដោយគោរពគ្នាទៅវិញទៅមក ។

ការទទួលយកនូវវប្បធម៌ថ្មី ក៏ជាសិទ្ធិរបស់បុគ្គលម្នាក់ៗផងដែរ ។ ប៉ុន្តែការទទួលនោះត្រូវមានបែបបទខ្លះដែរដោយមិនឱ្យជ្រុលហួសហេតុពេកដែលនាំឱ្យមានការប៉ះពាល់ដល់វប្បធម៌ និងប្រពៃណីរបស់ជាតិខ្លួននោះឡើយ ។

ចាប់តាំងពីសម័យកាលរហូតមក ការទទួលយកវប្បធម៌ដែល ហូរចេញពីប្រទេសដែលមានអារ្យធម៌ខ្ពង់ខ្ពស់ ឬសេដ្ឋកិច្ចជឿនលឿនជាកត្តាមិនអាចជៀសវាងបានឡើយ ។ ប៉ុន្តែការទទួលនោះក្នុងន័យនាំឱ្យប្រទេសមួយដែលទទួលនោះបានរីកចម្រើន ដោយរក្សាមិនឱ្យបាត់បង់អត្តសញ្ញាណជាតិរបស់ខ្លួនឡើយ ។

ការទទួលយកជ្រុលហួសហេតុ ភ្លេចប្រវត្តិរបស់ខ្លួន ភ្លេចជាតិ ភ្លេចវប្បធម៌របស់ខ្លួននោះ វាមិនគួរឱ្យកើតមានដែរ ។ ប្រទេសកម្ពុជាយើងមានវប្បធម៌ និងអរិយធម៌ ដ៏ប្រសើរផូរផង់ណាស់ គួរយើងទាំងអស់គ្នាការពារ និងអភិរក្សថែរក្សា ។

ក្នុងន័យនេះអ្នកនាំសារសូមលើកយកឧទាហរណ៍ថ្ងៃបុណ្យនៃសេចក្ដីស្រឡាញ់ដែលខិតជិតមកដល់នៅថ្ងៃខាងមុខនេះ ។

បើតាមវប្បធម៌បស្ចិមប្រទេសបុណ្យនេះមានអត្ថន័យជ្រៅស្របតាមប្រពៃណី និងវប្បធម៌ជាតិរបស់គេ ។ ប៉ុន្តែសម្រាប់ប្រជាជនកម្ពុជា ជាពិសេសយុវជនយុវនារី ដែលកំពុងទទួលឥទ្ធិពលនៃបុណ្យនេះត្រូវទទួលរងគ្រោះទៅវិញ គឺនាំឱ្យគេដើរផ្លូវមួយខុសជាពិសេសយុវនារី គឺត្រូវខូចអនាគតដោយចាញ់បោកជន ខិលខូចមួយចំនួនដែលឆ្លៀតឱកាស លួងលោមនារីឈានដល់ការរួមភេទមុនរៀបអាពាហ៍ពិពាហ៍ ដែលខុសនឹងប្រពៃណី និងនាំឱ្យខូចកិត្តិយសគ្រួសារ ។

តាមការស្រាវជ្រាវរបស់អ្នកជំនាញ មានយុវជនជាច្រើនដែលរៀបគម្រោងការ ដើរកំសាន្ដ ជូនអំណោយដល់ដៃគូរបស់ខ្លួន ហើយមួយចំនួនអាចឈានដល់ ការរួមភេទទៀតផង ។ ចំនុចទាំងនេះ អ្នកជំនាញបានអំពាវនាវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់អាណាព្យាបាល មាតាបិតា និងអាជ្ញាធរមានសត្ថកិច្ចចូលរួមអប់រំណែនាំ និងបកស្រាយ ឱ្យត្រឹមត្រូវអំពីអត្ថន័យរបស់បុណ្យនេះ ។

យុវជនគ្រីស្ដបរិស័ទគួរដើរតួជាអ្នកចាប់ផ្ដើម បកស្រាយ និងធ្វើជាគំរូដល់អ្នកឯទៀតៗ ! មនុស្សទាំងប្រុស ទាំងស្រីជារូបតំណាងរបស់ព្រះជាម្ចាស់ ! ជីវិតមានតម្លៃ !

## កម្មវិធីវិទ្យុព្រះសហគមន៍កាតូលិក

“ខ្ញុំត្រូវការអ្នក” ខែកុម្ភៈ ឆ្នាំ២០១១ (FM 99.5 Mhz ច័ន្ទ,អង្គារ ម៉ោង១០-១១ព្រឹក)

ថ្ងៃទី១ ខែកុម្ភៈ : យុវវ័យក្នុងឱកាសចូលឆ្នាំចិន។ ថ្ងៃទី៧ ខែកុម្ភៈ : មានសង្សារច្រើនមានមោទនភាព ឬយ៉ាងណា ? ថ្ងៃទី៨ ខែកុម្ភៈ : គម្រោងយុវវ័យនៅថ្ងៃបុណ្យនៃក្តីស្រឡាញ់។ ថ្ងៃទី១៤ ខែកុម្ភៈ : សោកនាដកម្មនៃថ្ងៃបុណ្យសង្សារ។ ថ្ងៃទី១៥ ខែកុម្ភៈ : យុវវ័យក្រោយថ្ងៃបុណ្យនៃក្តីស្រឡាញ់។ ថ្ងៃទី២១ កុម្ភៈ : ហិង្សាយុវតីនៅទីសាធារណៈ។ ថ្ងៃទី២២ ខែកុម្ភៈ : ទំនាក់ទំនងយុវវ័យបច្ចុប្បន្ន និងឪពុកម្ដាយ។ ថ្ងៃទី២៨ ខែកុម្ភៈ : ស្ត្រីពិការ និងតម្លៃក្នុងសង្គម។ ប្រធានបទទាំងនេះ មានវាគ្មិនជំនាញបកស្រាយ។**សូមកុំភ្លេចតាមដាន!**

## កម្មវិធីវិទ្យុព្រះសហគមន៍កាតូលិក

អ្នកចូលរួមកម្មវិធីអេម៉ានូអែល “សម្លេងពីព្រះសហគមន៏កាតូលិក” ខែកុម្ភៈ

-ថ្ងៃអាទិត្យទី០៦ ខែកុម្ភៈ ឆ្នាំ ២០១១ អាទិត្យទី៥ ក្នុងរដូវធម្មតា : ចូលរួមដោយលោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងស្វ៊ី ព្រះសហគមន៏កាតូលិកកំពង់ចាម។

-ថ្ងៃអាទិត្យទី១៣ ខែកុម្ភៈ ឆ្នាំ២០១១ អាទិត្យទី៦ ក្នុងរដូវធម្មតា : ចូលរួមដោយលោកបូជាចារ្យពេត្រូ កូស៏មែស៏ ព្រះសហគមន៏កាតូលិកបាត់ដំបង់។

-ថ្ងៃអាទិត្យទី២០ ខែកុម្ភៈ ឆ្នាំ ២០១១ អាទិត្យទី៧ ក្នុងរដូវធម្មតា : ចូលរួមដោយលោកបងប្រុសមួង រស់ និស្សិតទេវវិទ្យាល័យសន្តយ៉ូហានម៉ារី វីយ៉ាណេ រាជធានីភ្នំពេញ។

-ថ្ងៃអាទិត្យទី២៧ ខែកុម្ភៈ ឆ្នាំ២០១០ អាទិត្យទី៨ ក្នុងរដូវធម្មតា : ចូលរួមដោយលោកគ្រូដួង សារង្ស ប្រធានមណ្ឌលវប្បធម៌ព្រះសហគមន៏កាតូលិកនៅកម្ពុជា។

# សេដ្ឋកិច្ច

## អង្ករធ្លាក់ថ្លៃ ! អ្នកសេដ្ឋកិច្ចថា កុំអាលលក់

**ខាន់ ភីរម្យ**

សហគមន៍នៅក្នុងភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជាមួយបានអះអាងថា ស្រូវកំពុងតែធ្លាក់ថ្លៃ។ កសិករមួយចំនួនអាចនឹងប្រឈមមុខទៅនឹងការជំពាក់បំណុលពីស្ថាប័នមីក្រូហិរញ្ញវត្ថុ។

លោកសេងសុខហេង ជាប្រធានសហគមន៍ព្រៃឈើអណ្តូងបរ ស្រុកបន្ទាយមានជ័យខេត្តឧត្តរមានជ័យបានអះអាងថា ស្រូវម្លិះជាប្រភេទស្រូវក្រអូបនិងមានទីផ្សារនាំចេញនោះ ពេលនេះ គឺមានតម្លៃត្រឹមតែ ៦ទៅ ៧បាត ឬប្រហែល ១000រៀលតែប៉ុណ្ណោះក្នុងមួយគីឡូក្រាម។ លោកក៏បានអះអាងថា តម្លៃនេះអាចធ្វើឱ្យកសិករមួយចំនួនដែលជាប់បំណុលស្ថាប័នមីក្រូហិរញ្ញវត្ថុមានបញ្ហា ដោយសារពួកគាត់ក៏រំពឹងលើផលស្រូវដើម្បីសង។ លោកបានបញ្ជាក់ថា: "អ្នកស្រុកចងការគេដើម្បីយកទៅទិញម៉ាស៊ូត និងជីផ្សេងៗ។ ប៉ុន្តែដល់បានផលតម្លៃស្រូវថោកជាងឆ្នាំទៅរហូតដល់ទៅ៣បាតឯណោះ"។

លោកសុង ហុង ម្ចាស់រោងម៉ាស៊ីនកិនស្រូវមួយក្នុងខេត្តបាត់ដំបង មានប្រសាសន៍ថា តម្លៃស្រូវឆ្នាំនេះពិតជាថោកមែន តែមិនមែនតែនៅកម្ពុជាទេគឺនៅទីផ្សារអន្តរជាតិ ក៏ថោកដែរ។

ជុំវិញបញ្ហានៃការធ្លាក់ចុះតម្លៃស្រូវនេះ លោក



Photo : P.Samphy

សុខ ហាច ប្រធានវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជានិងជានាយកក្រុមហ៊ុន ហ្គោលដិនរ៉ាយ ដែលជាក្រុមហ៊ុននាំចេញអង្ករមួយចម្បង បានឱ្យដឹងថា តម្លៃស្រូវក្នុងប្រទេសពេលនេះគឺពិតជាស្រុតចុះច្រើន។ ប៉ុន្តែលោកអំពាវនាវឱ្យអ្នកស្រុករក្សាស្តុក។

លោកបានបញ្ជាក់ថា ស្រូវឆ្នាំទៅសម្ងួត ១តោនអាចលក់បាន ៤00ដុល្លារ។ តែនៅឆ្នាំនេះត្រឹមតែ ៣00ដុល្លារក្នុងមួយតោន។ តែបើកសិករចង់បានថ្លៃ សូមរក្សាទុក៤ ទៅ៥ខែសិន។ លោកបន្តថា: "ស្រូវនឹងឡើងថ្លៃវិញ កុំអាលលក់ឥឡូវ"។

ជុំវិញបញ្ហាជំពាក់បំណុលដោយសារតែការវិនិយោគទៅលើដំណាំស្រូវនេះ លោកហួត អេងតុង ប្រធានស្ថាប័នមីក្រូហិរញ្ញវត្ថុហត្ថាកសិករបានមានប្រសាសន៍ថា អាចមានតិចតួចទេ។ លោកបានឱ្យដឹងថាសមាគមមិនមានតួលេខជាផ្លូវការទេ។ ប៉ុន្តែបើតាមរយៈតួលេខរបស់ហត្ថាកសិករដែលលោកគ្រប់គ្រងផ្ទាល់នោះ។ ឥណទានមិនដំណើរការបានថយចុះពី ៣% នៅក្នុងឆ្នាំ ២00៩ មកនៅត្រឹមតែ 0.៩% តែប៉ុណ្ណោះ នៅក្នុងឆ្នាំ២0១0។

### នៅឆ្នាំ២០១១ គេរំពឹងថា កម្ពុជាអាចនាំចេញអង្ករបាន ១០០០០០ តោន

លោកសុខ ហាច បានមានប្រសាសន៍ថា តាមការរំពឹងទុក នៅក្នុងឆ្នាំ២០១១នេះ កម្ពុជាអាចនាំចេញអង្ករបានប្រមាណ ១០០០០០តោន។ លោកបានបញ្ជាក់ថា នៅក្នុងឆ្នាំ២០១០ កន្លងទៅ ទីផ្សារអង្ករកម្ពុជា មានប្រមាណ ៤០០០០តោន តែនៅក្នុងឆ្នាំ២០១១ នឹងឡើងដល់ ១០០០០០តោន។

លោកបានឱ្យដឹងទៀតថា ទីផ្សារអង្ករសំខាន់ជាងគេសម្រាប់កម្ពុជា ទាំងឆ្នាំនេះ និងឆ្នាំទៅ គឺទីផ្សារសហគមន៍អឺរ៉ុប។ លោកបានបញ្ជាក់ទៀតថា អឺរ៉ុបជាទីផ្សារអង្ករកម្ពុជាដែលស្រូបរហូតដល់ ៩៩%។ ក្រៅពីទីផ្សារអឺរ៉ុប នៅក្នុងឆ្នាំ២០១១នេះ ប្រទេសមួយចំនួននៅអាស៊ី ក៏បានចាប់អារម្មណ៍នឹងអង្ករកម្ពុជាផងដែរ។ ប្រទេសទាំងនោះមានដូចជា ម៉ាឡេស៊ី និងបង់ក្លាដេសជាដើម។

# សុខភាព

## អ្នកជំនាញ : "រក្សាប្រេវ៉ាឡង់អេដស៍ធ្លាក់ចុះ គឺយើងត្រូវបន្តការប្តេជ្ញា"

**ជាត សំភី**

យោងតាមតួលេខចុងក្រោយនៃមជ្ឈមណ្ឌលប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ សើស្បែក និងកាមរោគកម្ពុជាបានទទួលជោគជ័យក្នុងការកាត់បន្ថយអត្រាប្រេវ៉ាឡង់ចំនួនអ្នកផ្ទុកមេរោគអេសដ៍ពី២.0(២នាក់ ក្នុងចំណោម១00នាក់មាន ផ្ទុកមេរោគអេដស៍) នៅឆ្នាំ១៩៩៨ មកនៅត្រឹម 0.៩ នៅឆ្នាំ ២00៦ សម្រាប់អ្នកអាយុចន្លោះពី១៥ឆ្នាំ ដល់ ៤៩ឆ្នាំ។ ដូច្នេះកម្ពុជាបានទទួលការសរសើរពីអង្គការសហប្រជាជាតិក្នុងការឆ្លើយតបនឹងមេរោគអេដស៍ ដែលនេះ គឺជាគោលដៅទី៦ ក្នុងគោលដៅអភិវឌ្ឍសហស្សវត្សរ៍។

លោកទីម វ៉ា នាយកប្រតិបត្តិនៃគណៈកម្មាធិការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍ មានប្រសាសន៍ថា មានកត្តាជាច្រើន ដែលទាញទម្លាក់អត្រាប្រេវ៉ាឡងនេះ ទី១ គឺមានការប្តេជ្ញាចិត្តពីរាជរដ្ឋាភិបាល ដូចជាមានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ទី២ យើងមានការចូលរួមពីសង្គមស៊ីវិលនិងអ្នកដែលជាជនរងគ្រោះ ដើម្បីផែនការយុទ្ធសាស្ត្រអនុវត្ត និងការតាមដានវាយតម្លៃ។ ទី៣ យើងមានប្រព័ន្ធតាមដានជាក់លាក់ដែលរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងទី៤ គឺមានការចូលរួមពីអ្នកពាក់ព័ន្ធមានទាំងអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ផ្នែកឯកជន និងសាធារណជនដែលជាការងារពហុវិស័យ។



Photo : P. Lina

លោកទីម វ៉ា បញ្ជាក់ទៀតថា : "រក្សាប្រេវ៉ាឡង់ អេដស៍ធ្លាក់ចុះ គឺយើងត្រូវបន្តការប្តេជ្ញា"។ លោកក៏បន្តថា ទាំងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ម្ចាស់ជំនួយ និងសាធារណៈជនត្រូវចូលរួមសកម្មដើម្បីធ្វើការងារអេដស៍ ដូចជា សាងផែនការ អនុវត្តនិងស្វែងយល់ដើម្បី បង្ការខ្លួន...។



Photo : pha Lina

# បុណ្យនៃក្ដីស្រលាញ់មិនមែនជាប្រពៃណីរបស់ព្រះសហគមន៍កាតូលិក

**ខាន់ ភីរម្យ**

បុណ្យនៃក្ដីស្រលាញ់ តើជាថ្ងៃបង្ហាញនូវសេចក្ដីស្នេហ៍ដ៏ពិតប្រាកដ ឬជាថ្ងៃនៃសម្ដែងល្បែងស្នេហ៍ ឬជាថ្ងៃបង្ហាញនូវសេចក្ដីស្រលាញ់ដ៏ពិតប្រាកដ? នេះជាចម្ងល់របស់លោកអ៊ុន សុន បូជាចារ្យ ទទួលបន្ទុកព្រះសហគមន៍កំពត បានលើកឡើង ដើម្បីឱ្យយុវជនពិចារណា ។

លោកមានប្រសាសន៍ថា បុណ្យនៃក្ដីស្រលាញ់ ដែលយុវវ័យតែងតែអបអរយ៉ាងផុលផុសនៅក្នុងថ្ងៃទី១៤កុម្ភៈ មិនមែនជាប្រពៃណីរបស់ព្រះសហគមន៍ឡើយ ។ លោកក៏មានប្រសាសន៍បញ្ជាក់ថា: "ថ្ងៃនេះអត់មានក្នុងប្រតិទិនកាតូលិកឡើយ ប៉ុន្តែនៅ ព្រះវិហារមានធ្វើពិធីអភិបូជា ដើម្បីឱ្យបងប្អូនយល់ពីអត្ថន័យនៃក្ដីស្រលាញ់ដ៏ពិតប្រាកដ" ។

លោកតុង សុប្រាជ្ញ ជាអ្នកស្រាវជ្រាវឯករាជ្យ ហើយជាអ្នកដែលធ្លាប់ធ្វើការស្រាវជ្រាវពីស្នេហា និងទំនាក់ទំនងផ្លូវភេទនៅថ្ងៃបុណ្យសង្សារបានឱ្យដឹងថា យុវវ័យមួយចំនួនអាចនឹងបាត់បង់អនាគតដោយសារតែការភ្លើតភ្លើននៅក្នុងថ្ងៃនេះ ។ លោកបន្តថា យោងទៅតាមការសិក្សាមួយ ដែលលោកបានធ្វើកាលពីឆ្នាំ២០០៩ទៅលើយុវវ័យដែលស្ថិតនៅក្នុងឋានៈទ្រព្យសម្បត្តិបង្គួរចំនួន ៤៥៨នាក់ រកឃើញថា គឺមានយុវវ័យរហូតដល់ទៅ៥៨,៥% អះអាងថា ពួកគេនឹងមានផែនការជូនវត្ថុអនុស្សាវរីយ៍ទៅសង្សាររបស់គេ ។ ហើយមានយុវវ័យរហូតដល់ទៅ៩៩,៥% ក៏បានអះអាងថា ពួកគេមានគម្រោងដើរលេងជាមួយនឹងសង្សាររបស់ពួកគេ ហើយជាទីកន្លែងដែលពួកគេនឹងដើរលេងនោះមានផ្សេងៗគ្នា ។ ប៉ុន្តែមាន ១៩% បានអះអាងថា ពួកគេទៅក្លឹបកំសាន្ត ហើយវារឹតតែច្បាស់ទៅ ទៀតនោះ គឺមានយុវវ័យចំនួន២,៤% អះអាងថា ពួកគេមានផែនការទៅលេងខ្ទមតូចៗតាមមាត់ទឹក ផ្ទះសំណាក់និងនៅសណ្ឋាគារ ។ លោកបានបន្តទៀតថា អ្វីដែលច្បាស់ហើយជាការដែលយើងគួរព្រួយបារម្ភនោះ គឺថានៅពេលដែលយើងសួរថា តើពួកគេអាចនឹងរួមភេទនៅថ្ងៃបុណ្យសង្សារដែលនឹងមកដល់នៅក្នុងពេលឆាប់ៗខាងមុខនេះឬទេនោះ?ចម្លើយដែលថា "អាច"នោះគឺមានរហូតដល់ទៅ ១២,៤% ហើយចំពោះយុវវ័យ ដែលគេមានគូសង្សារស្រាប់ ទៅហើយនោះមានចំនួន ១៤,៣% ដែលបានអះអាងថា ពួកគេនឹងអាចរួមភេទ ។

លោកបន្តទៀតថានេះគឺជាលទ្ធផលដែលសិក្សានៅមុនថ្ងៃបុណ្យសង្សារ ប៉ុន្តែក្រោយពីលទ្ធផលនៃការសិក្សាស្រាវជ្រាវត្រូវប្រកាស និងការចូលរួមយុទ្ធនាការផ្សេងៗក្នុងឆ្នាំ២០១០កន្លងទៅសកម្មភាពយុវវ័យហាក់ដូចជាស្ងប់ស្ងាត់ជាងឆ្នាំមុនៗ ។

លោកបូជាចារ្យអ៊ុន សុន មានប្រសាសន៍ថានេះគឺជាបញ្ហាដែលគួរឱ្យព្រួយបារម្ភ ដូច្នេះហើយបានជាយើងធ្វើអភិបូជារួមគ្នាដើម្បីឱ្យយុវជន និងយុវនារីយល់អត្ថន័យនៃក្ដីស្រលាញ់ដ៏ពិតប្រាកដមួយ ។ លោកបញ្ជាក់ថា : "សេចក្ដីស្រលាញ់ មិនមែនមានត្រឹមតែជាស្នេហាស្រើបស្រាល វាអាចជាសេចក្ដីស្រលាញ់គ្រួសារឪពុកម្ដាយបងប្អូន" ។ លោកបានបន្តទៀតថា : "សូមយុវជន និងយុវនារី កុំឱ្យយកលេសថ្ងៃនេះឱ្យទៅជាស្នេហ៍ពុះកញ្ជ្រោល ។សេចក្ដីស្រលាញ់រវាងបុរស និងនារីដែលត្រឹមត្រូវ គឺស្មោះត្រង់ចូលស្ដីដណ្ដឹង ហើយទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍" ។

លោកតុង សុប្រាជ្ញ បានធ្វើការអំពាវនាវដែរថា យុវវ័យសូមកុំឱ្យភ្លើតភ្លើន ហើយអាជ្ញាធរ និងអ្នកជំនាញ និងក្រុមគ្រួសារអាណាព្យាបាលក៏គួរតែធ្វើសកម្មភាពផ្សេងៗដើម្បីទប់ស្កាត់លើបញ្ហានេះ ។ លោកបន្តថា ប្រសិនបើថ្លោះធ្លោយ គឺយុវវ័យទាំងនោះនឹងបាត់បង់កិត្តិយស អាចឆ្លងជំងឺអេដស៍ អាចខូចអនាគត ហើយក៏មានមួយចំនួនរហូតដល់អាចធ្វើអត្តឃាតផងដែរ ។

# កសិកម្ម

## សួនធម្មជាតិ និងបន្លែគាំទ្រសុខភាពអ្នកបរិភោគ

**ជាត សំភី**



Photo : P.Samphy

ស្របពេលមានការអភិវឌ្ឍន៍សេដ្ឋកិច្ច នៅក្នុងប្រទេស ការផលិតចំណីអាហារ ក៏ទាមទារឱ្យមានបរិមាណយ៉ាងច្រើន ដើម្បីបំពេញតម្រូវការរបស់ប្រជាជនដែលចេះតែកើនឡើង។ ដូច្នេះនៅលើទីផ្សារសព្វថ្ងៃ មានបន្លែផ្លែឈើមីដេរដាសដែលមានលាយចម្រុះដោយផលិតផលធម្មជាតិ និងផលិតផលគីមី។ ទោះបីជាយ៉ាងណាផលិតផលដែលធ្វើឡើងដោយប្រើជីធម្មជាតិកាន់តែត្រូវបានពេញនិយម ពីព្រោះវាមិនធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកបរិភោគទៅថ្ងៃក្រោយ។

ជាក់ស្តែងចំការបន្លែដែលគេដាក់ឈ្មោះថា សួនធម្មជាតិ បានដំណើរការតាំងពីឆ្នាំ២០០៩រហូតមកដល់សព្វថ្ងៃ ដោយមានការពេញនិយមពីអតិថិជនដែលយល់អំពីតម្លៃផលិតផលដែលមិនប្រើជាតិគីមី។សួនធម្មជាតិ គឺមានទីតាំងនៅភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល។

បន្លែដែលដាំនៅទីនោះ មានប្រភេទបន្លែដូចជាសាឡាដបរទេសចំនួន១១មុខនិងបន្លែខ្មែរមានដូចជា សណ្តែកគួរ សណ្តែក បារាំង ត្រប់វែង ត្រឡាចនននោង ល្ពៅ ពូហ្គូន ខាត់ណា ស្ពៃតឿ ស្ពៃផ្កា ស្ពៃខ្មៅ និងបន្លែជាច្រើនប្រភេទទៀត។

លោកកែវ វ៉ាឌី ដែលជាម្ចាស់សួនធម្មជាតិមានប្រសាសន៍ថា ការបង្កើតសួនធម្មជាតិនេះឡើង គឺក្នុងគោលដៅរក្សាសុខភាពអ្នកបរិភោគ ពោលគឺនៅពេលប្រទេសកាន់តែអភិវឌ្ឍ សុខភាពកាន់តែសំខាន់។ ទីពីរ គឺទាក់ទងនឹងទីផ្សារ លោកមានទីផ្សារនៅផ្សារបឹងកេងកង ដែលសម្បូរដោយជនបរទេស និងទីបី ចំការលោកមានទីតាំងល្អ គឺស្ថិតនៅលើកដីមានជីជាតិ។

លោកសោម សុទ្ធារិទ្ធ ជាអ្នកគ្រប់គ្រងដំណើរការចំការមានប្រសាសន៍ថា ការដាក់ឈ្មោះនេះថា គឺជាសួនធម្មជាតិ គឺ៩៩% នៃផលិតផលបន្លែរបស់លោក គឺចេញពីធម្មជាតិសុទ្ធសាធ ពោលគឺលោកប្រើជីកំប៉ុស្តសម្រាប់ស្រោចបន្លែ ផ្សំឡើងពីអាចម៍ប្រជៀវ ឬអាចម៍ក្របី។ ម្យ៉ាងវិញទៀតសូម្បីតែថ្នាំសម្លាប់សត្វល្អិតក៏ផ្សំឡើងពីធម្មជាតិដែរ។

លោកកែវ វ៉ាឌី បានបញ្ជាក់ឱ្យដឹងទៀតផងដែរថាអ្នកបរិភោគរាល់រូបគួរតែឱ្យតម្លៃលើផលិតផលដែលមិនប្រើសារធាតុគីមីឱ្យបានច្រើន ពីព្រោះទេវាមិនធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់គាត់ទៅថ្ងៃអនាគត។ ហើយប្រសិនបើអ្នកបរិភោគកាន់តែគាំទ្រនោះ កសិករក៏ងាកមកយកចិត្តទុកដាក់នឹងការផលិតផលធម្មជាតិដែរ។ លោកគូសបញ្ជាក់ទៀតថា ចំណែកខាងកសិករវិញ កន្លងមកគាត់មិនទាន់បានសិក្សាស្វែងយល់ និងអនុវត្តឱ្យបានស៊ីជម្រៅទៅលើកសិកម្មធម្មជាតិ។ តាមពិតជីធម្មជាតិមានច្រើនប្រភេទណាស់ដែលគាត់អាចធ្វើបាន។

---

បរិស្ថាន

## តើការប្រែប្រួលអាកាសធាតុនេះជះឥទ្ធិពលអ្វីខ្លះ?

ការប្រែប្រួលអាកាសធាតុកើតមានចាប់តាំងពីបដិវត្តន៍ឧស្សាហកម្មក្នុងសតវត្សទី១៨ និងទី១៩ ដែលបាននាំយកការរីកចម្រើនយ៉ាងខ្លាំងក្នុងវិស័យកសិកម្ម ឧស្សាហកម្ម ទូរគមនាគមន៍ និងការដឹកជញ្ជូន...។

នៅសតវត្សទី២០ ភស្តុតាងវិទ្យាសាស្ត្របានបង្ហាញកាន់តែច្បាស់ថា សកម្មភាពមនុស្សជាកត្តាចម្បងដែលនាំឱ្យមានការប្រែប្រួលអាកាសធាតុ។

នាពេលបច្ចុប្បន្ន ពិភពលោកកំពុងជួបប្រទះនឹងការខ្វះទឹក។ អ្នកវិទ្យាសាស្ត្រព្យាករណ៍ថា នឹងមានព្រឹត្តិការណ៍ អាកាសធាតុអាក្រក់ ឬគ្រោះមហន្តរាយកើតឡើងកាន់តែញឹកញាប់ និងមានសភាពធ្ងន់ធ្ងរជាងមុន។

វិស័យសំខាន់ៗ ដែលទទួលរងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុមាន :

-វិស័យធនធានទឹក : មានការប្រែប្រួលទាំងបរិមាណ គុណភាព និងការចែកចាយទឹក ហើយអាចនឹងបង្កឱ្យមានជម្លោះធនធានទឹករវាងប្រទេសនានាទៀតផង។

-ប្រព័ន្ធអេកូឡូស៊ី : បាត់បង់ទីជម្រក និងផុតពូជនូវអំបូរសត្វមួយចំនួន និងប្រែប្រួលសមាសធាតុព្រៃឈើ។

-តំបន់ឆ្នេរ : មានសំណឹក កំណើនកម្ពស់ទឹកសមុទ្រអាចបង្កឱ្យមានទឹកជំនន់។

-សុខភាពមនុស្ស : ការរីករាលដាលជំងឺឆ្លង និងមេរោគដែលឆ្លងតាមរយៈការប្រើប្រាស់ទឹកមិនស្អាត មរណភាពដោយកំណើនសីតុណ្ហភាព និងបញ្ហាសុខភាពជាច្រើនទៀត។

-វិស័យកសិកម្ម : ទិន្នផលកសិកម្មប្រែប្រួល តម្រូវការធារាសាស្ត្រកើនឡើង ហើយដំណាំទាំងឡាយត្រូវប្រឈមនឹងការឆ្លងជំងឺ និងសត្វល្អិតចង្រៃបំផ្លាញ។

**ជីរេស**



Photo : DR

# អង្គការព្រះសហគមន៍កាតូលិក
## ជំនាញគំនូរអាចជួយគាំទ្រយុវជនឱ្យអាចរកចំណូលផ្គត់ខ្លួនឯង

**ជាត សំភី**

វគ្គសិក្សាគំនូររយៈពេល២ឆ្នាំដែលបង្កើតឡើងដោយអង្គការការីតាសតាំងពីឆ្នាំ២០០៦ ត្រូវបានផ្ដល់ជូនយុវជនគ្មានលទ្ធភាពបន្តការសិក្សាឱ្យអាចរកបាននូវអនាគតប្រសើរជាងមុន។

វគ្គសិក្សានេះស្ថិតនៅក្នុងកម្មវិធីអភិវឌ្ឍន៍យុវជនអង្គការការីតាស ដែលធ្វើឡើងនៅភូមិតាក្ដុល ឃុំតាក្ដុល ស្រុកតាខ្មៅ ខេត្តកណ្ដាល។ យុវជនចំនួន ១០នាក់កំពុងសិក្សាជំនាញ គំនូរសព្វថ្ងៃ ។

សារី ភីរម្យ ប្រធានកម្មវិធីអភិវឌ្ឍន៍យុវជននៅអង្គការការីតាសមានប្រសាសន៍ឱ្យដឹងថា: "ជំនាញគំនូរនេះ ត្រូវបង្កើតឡើងក្នុងបំណងឱ្យយុវជនមានជំនាញពិតប្រាកដ ដើម្បីឱ្យគាត់ងាយរកការងារធ្វើ និងរកកម្រៃចិញ្ចឹមជីវិត ហើយពេលបានកម្រៃគាត់អាចផ្គត់ផ្គង់គ្រួសារ និងធ្វើការរៀនបន្តផងដែរ"។

កញ្ញាសារី ភីរម្យ បានឱ្យដឹងទៀតថា ក្រៅពីការបង្រៀនវគ្គជំនាញនេះ អង្គការការីតាសក៏បានផ្ដល់អាហារបីពេលដល់យុវជនផងដែរ។ ចំពោះយុវជនមានទីលំនៅឆ្ងាយ គឺអង្គការការីតាសផ្ដល់ជាកន្លែងស្នាក់នៅសម្រាប់ពួកគេ។

ក្រៅអំពីការរៀនសូត្រ អង្គការការីតាសក៏បានជំរុញឱ្យយុវជនចូលរួមក្នុងសកម្មភាពផ្សេងៗ ដូចជា ការចូលរួមក្នុងទិវាសិទ្ធមនុស្ស ទិវាសិទ្ធនារី ទិវាបរិស្ថាន ទិវា១០ធ្នូ ឬអ្វីផ្សេងៗទៀត។ ម្យ៉ាងទៀត ការសិក្សាពីបំណិនជីវិតផ្សេងៗ ដូចជាការអញ្ជើញគ្រូមកបង្រៀនពីសុខភាពផ្លូវភេទ ឬពីអំពើហិង្សាក្នុងគ្រួសារក៏ត្រូវបានផ្ដល់ជូនយុវជនផងដែរ។

លោកឆយ សុខជា ជាគ្រូបង្រៀនគំនូរបានមានប្រសាសន៍ឱ្យដឹងថា ឆ្នាំទី១ យើងបង្រៀនសិស្សពីមូលដ្ឋានគ្រឹះនៃការប្រើប្រាស់ខ្មៅដៃ និងសិក្សាពន្លឺស្រមោល...។ ឆ្នាំទី២ យើងសិក្សាអំពីពណ៌ប្រេង ដែលវាជាជំនាញសម្រាប់ពួកគាត់ប្រើប្រាស់ដើម្បីប្រកបរបរចិញ្ចឹមជីវិត។

លោកឆយ សុខជាបន្តទៀតថា តាមរយៈការបណ្ដុះបណ្ដាលកន្លងមក សិស្សដែលចេញទៅ អាចមានលទ្ធភាពទៅធ្វើ ការងារនៅតាមអង្គការផ្សេងៗ ឬបើកជាអាជីវកម្មផ្ទាល់ខ្លួនឯងផងដែរ។ លោកបញ្ជាក់ថា សូម្បីតែសិស្សកំពុងរៀនក៏គាត់អាចរកចំណូលបានផងដែរ តាមរយៈការលក់ គំនូររបស់ពួកគេទៅកាន់ម៉ូយនៅរាជធានីភ្នំពេញដូចជានៅផ្សារទួលទំពូង ឬសាលាវិចិត្រសិល្បៈជាដើម។



Photos : P. Samphy

**យុវជនរស់ ដួងពិសិដ្ឋ ធ្វើការយ៉ាងជក់ចិត្តជាមួយគំនូររបស់ខ្លួនដោយសង្ឃឹមលើជំនាញនេះចិញ្ចឹមជីវិតក្នុងថ្ងៃអនាគត**

ហើយគំនូរដែលពួកគេគូរភាគច្រើន គឺទាក់ទងនឹងវប្បធម៌រូបអប្សរារូបអង្គរវត្ត ឬរូបធម្មជាតិស្អាតៗ ដែលសម្បូរអតិថិជនទិញ។

វ៉ាន់ ដែន អាយុ ២៤ឆ្នាំ មានស្រុកកំណើតនៅភូមិកអង្គ ឃុំកអង្គ ស្រុកពាមជរ ខេត្តព្រៃវែង បានឱ្យដឹងថា: "ខ្ញុំសប្បាយចិត្ត ពីព្រោះបានរៀនជំនាញពិតប្រាកដ"។ លោកបន្តថា ជាមួយនឹងជំនាញនេះ លោកអាចរកចំណូលបាន ក្នុងមួយសប្ដាហ៍ៗ គឺបានប្រហែល ១០០ដុល្លារដែរ អាស្រ័យទៅតាមការបញ្ជាទិញ។ លោកគូសបញ្ជាក់ថា: "ខ្ញុំមានគម្រោងពង្រីងអាជីពផ្ទាល់ខ្លួននេះឱ្យបានខ្លាំង"។

ចំណែកយុវជនរស់ ដួងពិសិដ្ឋ អាយុ ១៩ឆ្នាំមកពីទីក្រុងភ្នំពេញភូមិត្នោតជ្រំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យរាជធានីភ្នំពេញបាននិយាយដែរថា លោកសប្បាយចិត្ត ពីព្រោះលោកមានជំនាញពិតប្រាកដដែលអាចចិញ្ចឹមជីវិតទៅថ្ងៃក្រោយ។ ក្រៅពីនេះ លោកទទួលបានចំណេះដឹងជាច្រើនពីអង្គការការីតាស អង្គការនេះផ្ដល់នូវការអប់រំផ្សេងៗ និងជំរុញ



ឱ្យមានការចូលរួមជាមួយសង្គម។ លោកក៏បញ្ជាក់ថា: "ក្នុងមួយសប្ដាហ៍ខ្ញុំអាចរកចំណូលបាន ១០ ទៅ ១៥ដុល្លារ។ ប្រាក់នេះជួយខ្ញុំមិនឱ្យពឹងផ្អែកទៅលើឪម្ដាយទាំងស្រុង"។ លោកបញ្ជាក់ថា: "ខ្ញុំនឹងចាប់អាជីពនេះឱ្យជាប់ និងខំសន្សំប្រាក់ដើម្បីបើកអាជីវកម្មខ្លួនឯង "។

ចំណែកយុវជនយម៉ារ៉ាវុទ្ធ មកពីខេត្តបន្ទាយមានជ័យ នៅភូមិគៀ្យឃុំទឹកថ្លា ស្រុកសិរីសោភ័ណ្ឌ បាននិយាយថា: "ខ្ញុំមានអារម្មណ៍សប្បាយចិត្តណាស់ ពីព្រោះអាជីពគំនូរនេះជាក្ដីសុបិនតាំងពីខ្ញុំនៅក្មេង។ ឥឡូវអង្គការការីតាសផ្ដល់ឱកាសឱ្យខ្ញុំបានសិក្សា។ ហើយមកដល់ពេលនេះខ្ញុំអាចរកចំណូលបានតិចតួចដែរគឺពី១០ ទៅ១៥ដុល្លារក្នុងមួយសប្ដាហ៍ដែលអាចឱ្យខ្ញុំសន្សំប្រាក់ដើម្បីទៅរៀនបន្តនៅសាលាវិចិត្រសិល្បៈ"។ លោកគូសបញ្ជាក់ដែរថា: "ទៅថ្ងៃអនាគត ខ្ញុំចង់ក្លាយទៅជាអ្នកគំនូរដ៏ល្បីនៅទូទាំងប្រទេស"។

ក្រៅពីវគ្គសិក្សាគំនូរ កម្មវិធីអភិវឌ្ឍន៍យុវជនរបស់ការីតាស ខេត្តកណ្ដាល ក៏បានផ្ដល់ការបណ្ដុះបណ្ដាលជំនាញរយៈពេលខ្លី និងវែងជាច្រើនទៀតដល់យុវជនដូចជា គណនេយ្យ និងហិរញ្ញវត្ថុ លេខាធិការ និងរដ្ឋបាល វិទ្យាសាស្ត្រកំព្យូទ័រ អភិវឌ្ឍន៍សហគមន៍ អ៊ុតសក់ និងកែសម្ផស្ស ជួសជុលម៉ូតូ ជួសជុលអេឡិចត្រូនិច ជួសជុលរថយន្តតូចធំ និងតបណ្ដាញអគ្គិសនី ជួសជុលទូរសព្ទដៃ គ្រប់គ្រងភោជនីយដ្ឋាន និងជួសជុលបរិក្ខារម៉ាស៊ីនត្រជាក់...។


Photo : Chan Narong

ខាន់ ភិរម្យ

## អ្នកប្រើប្រាស់ទូរស័ព្ទដៃ នៅកម្ពុជា កើនដល់៩,៨លាននាក់

ក្រសួងប្រៃសណីយ៍ និងទូរគមនា-គមន៍ បានអះអាងថា ចំនួនអ្នកប្រើប្រាស់ ទូរស័ព្ទដៃនៅកម្ពុជា មកដល់ដំណាច់ឆ្នាំ ២០១០ បានកើនឡើងដល់ជិត ១០លាននាក់ ។

ឯកឧត្តមសូរ ឃុន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានប្រសាសន៍កាលពាក់កណ្តាលខែមករាថា ចំនួនអ្នកដែលបានចុះឈ្មោះ ប្រើប្រាស់ទូរស័ព្ទដៃនៅប្រទេសកម្ពុជា បានកើនដល់ចំនួន ៩.៨ លាននាក់ ហើយអ្នកចុះឈ្មោះ ប្រើប្រាស់ អ៊ីនធឺណិតមានចំនួន ១៧៣.៦៧៥នាក់ ។

លោកបានឱ្យដឹងទៀតថា កម្ពុជាមានក្រុមហ៊ុនទូរស័ព្ទចល័ត ចំនួន៩ មានបង្គោលអង់តែន ប្រមាណ៥០០០បង្គោល និងមានខ្សែកាបអុបទិច ចម្ងាយ ២០០០០គម ។ ក្រៅពីនោះកម្ពុជាមានក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតធំៗ ចំនួន ១៥ ក្រុមហ៊ុន ។

ឯកឧត្តមបញ្ជាក់ថា សព្វថ្ងៃនេះវិស័យបច្ចេកវិទ្យាទូរគមនាគមន៍កម្ពុជា មិនចាញ់បណ្តាប្រទេសនៅក្នុងតំបន់ឡើយ ។

### កម្ពុជាធ្វើជាម្ចាស់ផ្ទះវេទិកាទេសចរណ៍អាស៊ាន

កាលពីថ្ងៃទី១៨ ខែមករា កម្ពុជាបានធ្វើជាម្ចាស់ផ្ទះវេទិកាទេសចរណ៍អាស៊ាននៅកោះពេជ្រ រាជធានីភ្នំពេញ ដោយមានការចូលរួមពីបណ្តារដ្ឋមន្ត្រីក្រសួងទេសចរណ៍អាស៊ានទាំងអស់ក្រោមអធិបតីភាពរបស់ប្រមុខរដ្ឋាភិបាលកម្ពុជា ។

ឯកឧត្តមថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍មានប្រសាសន៍ថា វេទិកាទេសចរណ៍អាស៊ានលើកទី៣០នេះ ធ្វើឡើងក្រោមប្រធានបទ "អាស៊ានពិភពអច្ឆរិយៈ និងពិពិធភាព" ។ ឯកឧត្តមឱ្យដឹងថា ឆ្នាំ២០១០ អាស៊ានស្រូបយកទេសចរណ៍ចំនួន ៦៥លាននាក់ ក្នុងនោះកម្ពុជាអាចទាក់ទាញបានប្រមាណ២,៥ លាននាក់ដែលផ្តល់ការងារដល់ប្រជាជនប្រមាណ ៤០ម៉ឺននាក់ ។ ឯកឧត្តមបន្តថា ឆ្នាំ ២០១៣ កម្ពុជាគ្រោងនឹងទាក់ទាញ ភ្ញៀវទេសចរណ៍ឱ្យបាន៣,៥លាននាក់ ។

### សេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០១១ ទទួលបានកំណើន ៧%

នៅក្នុងឆ្នាំ ២០១១នេះ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាបានអះអាងថា កម្ពុជានឹងអាចទទួលកំណើន ៧%ដោយសារតែកំណើននៅក្នុងឆ្នាំ២០១០ ។

លោកឃិន ពិសី អ្នកស្រាវជ្រាវនៃវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាបានឱ្យដឹងថា នៅឆ្នាំ២០១០ កន្លងទៅនេះ កម្ពុជា ទទួលបានកំណើនសេដ្ឋកិច្ច ៦,៥% ហើយនៅក្នុងឆ្នាំ២០១១នេះ កម្ពុជា នឹងទទួលបានកំណើន ៧% ។ លោកបានបញ្ជាក់ថា ក្នុងឆ្នាំ២០១០ កសិកម្ម ទទួលបានកំណើនពី ៦ទៅ ៨,៤% វិស័យកាត់ដេរទទួលបានកំណើន ប្រមាណជា១៤,៥% កសិឧស្សាហកម្មកំណើនប្រមាណ ១៣,៣% វិស័យទេសចរណ៍ និងសណ្ឋាគារទទួលកំណើន ៩,៣% និងដោយឡែកវិស័យពាណិជ្ជកម្មទទួលកំណើនប្រមាណ៦,៦% ។

លទ្ធផលនៃការព្យាករណ៍នេះ គឺប្រសើរជាងការព្យាករណ៍របស់រដ្ឋាភិបាល ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងអង្គការរូបិយវត្ថុ ពិភពលោក ដែលបានទស្សន៍ទាយថា កំណើនរបស់កម្ពុជាគឺនៅចន្លោះពី ៦ទៅ ៦,៨% ។

## រដ្ឋាភិបាលហ្វីលីពីន និងឧទ្ទាមបើកធ្វើការចរចាសន្តិភាព

ដំណោះស្រាយសន្តិភាពរវាងរដ្ឋាភិបាលហ្វីលីពីន និងក្រុមឧទ្ទាមកុំម្មុយនីស្តនៅក្នុងប្រទេសដែលជាប់គាំងអស់រយៈពេលប្រមាណ៦ឆ្នាំមកហើយនោះ នឹងបើកការចរចាជាថ្មីនៅខែកុម្ភៈ។

យោងទៅតាមទីភ្នាក់ងារព័ត៌មានបារាំងបានឱ្យដឹងថា រដ្ឋាភិបាលប្រទេសហ្វីលីពីនក្រោមការដឹកនាំរបស់លោកបេនីកណូ អាគីណូ និងរណសិរ្សប្រជាធិបតេយ្យជាតិរបស់កុំម្មុយនីស្ត បានព្រមព្រៀងគ្នារួចហើយថា ពួកគេនឹងបន្តការពិភាក្សាទៅមុខ។

លោកអេដេនី ឡាសៀដា អ្នកនាំពាក្យលោកអាគីណូ បានអះអាងថា រដ្ឋាភិបាលហ្វីលីពីនពេញចិត្តនឹងការវិវត្តទៅមុខ ចំពោះផែនការចរចានេះ។ លោក បានឱ្យដឹងទៀតថា នេះគឺ ជាកាយវិការដំបូងប្រកបដោយភាពជឿ ជាក់នៃភាគីទាំងពីរ ដើម្បីចរចាសន្តិភាព។

## បក្សកុំម្មុយនីស្តវៀតណាមជ្រើសរើសអគ្គលេខាបក្សថ្មី តែនាយករដ្ឋមន្ត្រីនៅដដែល

សមាជគណបក្សកុំម្មុយនីស្តវៀតណាម កាលពីពាក់កណ្តាលខែមករាកន្លងទៅនេះ បានសម្រេចជ្រើសរើសមេដឹកនាំបក្សថ្មី ។ប៉ុន្តែរក្សាអ្នកកាន់ដំណែងជានាយករដ្ឋមន្ត្រីដដែល ។

បណ្តាញព័តមានអេភី បានអះអាងថា លោកណុង ដឹកម៉ាញ់ ជាអគ្គលេខាធិការបក្សកុំម្មុយនីស្តវៀតណាម បានបញ្ចប់ អាណត្តិរបស់លោកក្រោយពេលដែលលោកកាន់កាប់តំណែងនេះបាន១០ឆ្នាំ ហើយជំនួសដោយលោកឃ្វៀន ភូទ្រើង ដែលមានវ័យ ៦៦ឆ្នាំ អតីតជាប្រធានសភាវៀតណាម ។

លោកឃ្វៀន ថាន់ឌុង ដែលមានវ័យ ៦១ឆ្នាំ ហើយជានាយករដ្ឋមន្ត្រីអាណត្តិមុនបានត្រូវគេរំពឹងថា នឹងអាចរក្សាតំណែងនៅដដែល បើទោះបីជារដ្ឋបាលរបស់លោក នៅក្នុងរយៈពេលចុងក្រោយនេះ បានរងនូវការរិះគន់អំពីនយោបាយសេដ្ឋកិច្ច និងរឿងរ៉ាវដែលពាក់ព័ន្ធនឹងការដួលរលំនូវក្រុមហ៊ុនដឹកជញ្ជូនថ្នាក់ជាតិមួយដ៏ធំ ។

នៅក្នុងឆ្នាំ២០១០ នេះសេដ្ឋកិច្ចវៀតណាម បានត្រូវគេអះអាងថា ទទួលបានកំណើនប្រមាណ ៧% ។ តែអតិផរណាវិញ មានការកើនឡើង ជាហេតុធ្វើឱ្យតម្លៃស្បៀងអាហារ ពាណិជ្ជកម្ម និង ថវិការដ្ឋជួបបញ្ហា ។



Photo : DR

# ល្បុក្កតោ! ក្បាច់គុណបុរាណខ្មែរមានការទទួលស្គាល់

**ខាន់ ភីរម្យ**

*ក្បាច់គុណនៅកម្ពុជាសព្វថ្ងៃនេះ មានច្រើន ដូចជា តៃក្វាន់ដូ និងការ៉ាតេដូជាដើម។ ប៉ុន្តែក្នុងចំណោមក្បាច់គុណទាំងអស់នោះ គឺមានតែក្បាច់ល្បុក្កតោមួយគត់ដែលគេបានអះអាងថា ជារបស់ខ្មែរ។ ដើម្បីឱ្យយល់ថា តើល្បុក្កតោមានការទទួលស្គាល់បែបណា ? អ្នកនាំសារ សូមណែនាំមិត្តអ្នកអានឱ្យជួបលោកសាន គឹមស៊ាន ជាប្រធានសហព័ន្ធកីឡាល្បុក្កតោកម្ពុជា។*


Photo : DR

លោកសាន គឹម ស៊ាន ថតរូបអនុស្សាវរីយ៍បង្ហាញក្បាច់ល្បុកតោខ្មែរ ជាមួយលោកគ្រូវិជ្ជាគុណបរទេស

**អ្នកនាំសារ : តើហេតុអ្វីបានជាលោកចាប់អារម្មណ៍ក្នុងការបង្កើតជាសហព័ន្ធកីឡាល្បុក្កតោនេះឡើង ?**

**លោកសាន គឹមស៊ាន :** គោលបំណងសំខាន់នៃការបង្កើតសហព័ន្ធកីឡាល្បុក្កតោនេះឡើង គឺជាគំនិតនិងជាស្មារតីរបស់ខ្ញុំ និងចាស់ព្រឹទ្ធាចារ្យខ្មែរ១ចំនួនមានបំណងចង់អភិរក្ស និងរក្សានូវកេរ្តិ៍ដំណែលដែលបុព្វបុរសលោកបានបន្សល់ទុក ។ សហព័ន្ធនេះគឺថ្នាល់មួយដើម្បីសាបព្រោះ បណ្តុះវប្បធម៌ និងប្រពៃណីខ្មែរសម័យបុរាណឱ្យគង់វង្ស ។

**អ្នកនាំសារ : តើសហព័ន្ធកីឡាល្បុក្កតោមានការរីកចម្រើនប៉ុណ្ណាមកដល់សព្វថ្ងៃនេះ?**

**លោកសាន គឹមស៊ាន :** សហព័ន្ធបានចាប់កំណើតឡើងតាំងតែពីខែមេសា ឆ្នាំ២០០៤ ដោយបាតដៃទទេ ដោយក្នុងនោះមានតែខ្ញុំ និងព្រឹទ្ធាចារ្យមួយចំនួនតែប៉ុណ្ណោះ ។ ពេលនោះស្រទាប់សាធារណជនទូទៅមិនសូវស្គាល់ក្បាច់ល្បុក្កតោនេះទេ ប៉ុន្តែសព្វថ្ងៃគឺខុសគ្នា ។ សព្វថ្ងៃនេះយើង គឺជាសមាជិករបស់គណៈកម្មាធិការកីឡាជាតិអូឡាំពិក ។

**អ្នកនាំសារ : តើសហព័ន្ធមានសមាជិកទាំងអស់ប៉ុន្មាននាក់?**

**លោកសាន គឹមស៊ាន :** យើងនៅមិនទាន់បានធ្វើស្ថិតិឱ្យបានពិតប្រាកដនៅឡើយទេ។ ប៉ុន្តែយើងមានសមាជិកនៅ ១០ខេត្ត និងក្រុង ដោយខេត្តនីមួយៗមានសាលាគុណពី២ ទៅ៣កន្លែង ។ យើងគិតថា មកដល់ពេលបច្ចុប្បន្ននេះ យើងមានសមាជិកច្រើន ។ នៅរៀងរាល់ ការប្រកួតជម្រើសជាតិជារៀងរាល់ឆ្នាំនោះ យើងទទួលបានកំណើននៃការចុះឈ្មោះកាន់តែច្រើន ជាពិសេសគឺក្មេងៗ ជំនាន់ក្រោយ ។

**អ្នកនាំសារ : តើសហព័ន្ធនឹងធ្វើអ្វីដើម្បីរក្សាក្បាច់គុណឱ្យគង់វង្ស និងបន្តរីកចម្រើនទៅថ្ងៃអនាគត?**

**លោកសាន គឹមស៊ាន :** វាគឺជាទស្សនវិស័យ និង ជាអ្វីដែលសហព័ន្ធបានកំពុងតែធ្វើ គឺជំរុញក្មេងជំនាន់ក្រោយចាប់អារម្មណ៍នឹងក្បាច់គុណជាតិ ។ សហព័ន្ធជាថ្នាលបណ្តុះពូជវប្បធម៌ និងប្រពៃណីខ្មែរហើយ យើងតែងតែលើកទឹកចិត្តក្មេងជំនាន់ក្រោយ ។

**អ្នកនាំសារ : តើការរៀបចំកម្រិតថ្នាក់នៃការហ្វឹកហាត់នោះមានការខុសពីក្បាច់គុណបរទេសយ៉ាងដូចម្តេចដែរ?**

**លោកសាន គឹមស៊ាន :** នៅសម័យបុរាណបុព្វបុរសរបស់យើងមិនមានរៀបចំទៅជាកម្រិតថ្នាក់ ឬខ្សែក្រវាត់អ្វីនោះទេ ។ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះសហព័ន្ធបានចងក្រងក្បួនច្បាប់ចាស់រក្សាទុក ហើយបានរៀបចំជាកម្រិតថ្នាក់ជា ១៥កម្រិត ដូចជាក្បាច់គុណការ៉ាតេ ឬតៃក្វាន់ដូដែរ ។ ប៉ុន្តែយើង មិនហៅថា ខ្សែក្រវាត់ទេ យើងហៅថា ក្រម៉ា ។ ពេលចូលហាត់ដំបូង គេទទួលបានក្រមា ស បន្ទាប់ មកបៃតង ខៀវ ក្រហម ត្នោត និងខ្មៅ ជាន់ទី១ រហូតដល់ក្រម៉ាខ្មៅ ១០ ជាន់ ។


Photo : DR

សិស្សនៅក្នុងក្លឹបល្បុកតោខ្មែរ ដែលកំពុងតែរឹកដុះដាលនៅសង្កាត់ចាក់អង្រែ រាជធានីភ្នំពេញ។ វិជ្ជាគុណល្បុកតោ មិនគ្រាន់តែជាក្បាច់សម្រាប់ហាត់ការពារខ្លួន និងសុខភាពប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាកេរ្តិ៍ដំណែលបុព្វបុរសពីបុរាណផងដែរ។

### ល្បុក្កតោទទួលការគាំទ្រពីអន្តរជាតិ

លោកសាន គឹមស៊ាន ប្រធានសហព័ន្ធកីឡាល្បុក្កតោកម្ពុជា បានមានប្រសាសន៍ឱ្យដឹងថា ក្បាច់គុណល្បុក្កតោ មិនត្រឹមតែទាក់ទាញការចាប់អារម្មណ៍ពីសំណាក់ប្រជាពលរដ្ឋកម្ពុជានោះទេ សូមបីតែជនបរទេសក៏កំពុងតែចាប់អារម្មណ៍ចំពោះក្បាច់គុណផងដែរ។

លោកបានឱ្យដឹងថា មកដល់ឆ្នាំ២០១០កន្លងទៅនេះ សហព័ន្ធបានទទួលសិស្សមួយចំនួនមកពីប្រទេសអូស្ត្រាលី អាម៉េរិក អង់គ្លេស បារាំង អៃឡង់ ដាណឺម៉ាក ន័រវេស្ស និង ឥណ្ឌាផងដែរ។

លោកបានបន្តទៀតថា ហើយអ្វីដែលសំខាន់បំផុតនៅក្នុងឆ្នាំ២០១០នោះ គឺសហព័ន្ធបានក្លាយទៅជាសមាជិកមួយ នៃសមាគមសេរ៉ាសន្តិសុខ និងអង្គរក្សអន្តរជាតិដែលមានសមាជិកទាំងអស់ចំនួន ១៣០ប្រទេស។

# អ្នកជំនាញ : "អាជីវកម្មខ្នាតតូចប្រភពការងារដ៏សំខ

**ខាន់ ភីរម្យ**



"ជាមួយនឹងរទេះរុញមួយដែលមានបន្លែសឹងតែគ្រប់មុខមានត្រី មានសាច់ ខ្ញុំតែងតែរុញដើរនៅតាមដងផ្លូវនៅក្នុងទីក្រុងភ្នំពេញ វាគឺជាអាជីវកម្មមួយដែលផ្តល់នូវប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសារខ្ញុំ"។ នេះបើតាមការអះអាងរបស់អ្នកស្រីជា រ៉ា។

អ្នកស្រីជា រ៉ា បានឱ្យដឹងថា គាត់បានចាប់ផ្តើមរបរនេះតាំងតែចុងឆ្នាំ២០០៩ ដោយដើរលក់ហើយបានសន្សំប្រាក់ចំណេញរហូតបានទិញជារទេះរុញមួយកាលពីដើមឆ្នាំ២០១០។ អ្នកស្រីឱ្យដឹងទៀតថាជាមួយនឹងមុខរបរសាមញ្ញនេះ អាចជួយអ្នកស្រីចិញ្ចឹមគ្រួសារបានមួយ ដែលមានសមាជិក ៥នាក់ជាមួយនឹងប្រាក់ចំណេញ នៅក្នុងមួយថ្ងៃជាមធ្យមពី៣០០០០រៀល ទៅ៤០០០០រៀល។ អ្នកស្រីបានបញ្ជាក់ថា: "ទាំងដើមទាំងចុងមួយថ្ងៃហោចណាស់ក៏ពី១៥០០០០រៀលទៅ២០០០០០រៀលដែរ"។

អ្នកស្រីបានឱ្យដឹងថាគំនិតនៃការបង្កើតមុខរបរចម្រើនសព្វថ្ងៃនេះ បានមកពីការដែលអ្នកស្រី មិនមានធនធាននិងកង្វះកន្លែងសម្រាប់លក់នៅទីផ្សារដែលមានមនុស្សច្រើនចង្អៀត ហើយកន្លែងជួលថ្លៃ និងលក់ក៏មិនចំណេញ។

អ្នកស្រីនិយាយថា : "ឥឡូវបើសុំកន្លែងគេលក់ត្រឹមតែមួយកញ្ច្រែងទេ គឺគេទារមួយថ្ងៃដល់ ទៅ១៥០០០រៀល ទៅ២០០០០រៀល ចុះនៅថ្លៃអនាម័យ និងសណ្តាប់ធ្នាប់ទៀត តើខ្ញុំបានអ្វីចិញ្ចឹមកូន? អ៊ីចឹងហើយបានខ្ញុំចេញមកលក់នៅតាមដងផ្លូវ"។

អាជីវកម្មប្រភេទនេះ ត្រូវបានគេឃើញមានជាបន្តបន្ទាប់នៅតាមដងផ្លូវនានាក្នុងទីក្រុងភ្នំពេញខណៈដែលមនុស្សកាន់តែរវល់ ហើយក៏គ្មានពេលវេលាគ្រប់គ្រាន់ទៅផ្សារដូចពីមុន។

អាជីវកម្មប្រភេទនេះ គឺជាឧទាហរណ៍ប្រភេទអាជីវកម្មខ្នាតតូច ដែលកំពុងតែផ្តល់ប្រាក់ចំណូលដ៏សមរម្យដល់អ្នកធ្វើខណៈដែលអ្នកជំនាញអះអាងថា វាកំពុងតែដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យសេដ្ឋកិច្ច និងទីផ្សារពលកម្មនៅកម្ពុជា។

លោកម៉ាតធូ ហ្គាមសឺ (Matthew Gamser) ប្រធានផ្នែកសេវាកម្មប្រឹក្សាយោបល់របស់អង្គការសាជីវកម្មហិរញ្ញវត្ថុ អន្តរជាតិប្រចាំអាស៊ីបូព៌ា និងប៉ាស៊ីហ្វិកបានឱ្យដឹងថា នៅកម្ពុជាសហគ្រាសខ្នាតតូច និងមធ្យមគឺជាប្រភពកំណើន និងជាទីផ្សារការងារមួយដ៏ចម្បង។

ជុំវិញបញ្ហានេះ ប្រធានសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា បានអះអាងកាលពីពេលថ្មីៗកន្លងទៅនេះថា សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជាកំពុងតែគ្របដណ្តប់សឹងតែលើគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជា ដូចជា កសិកម្ម សេវាកម្ម សិប្បកម្ម និងឧស្សាហកម្ម...។

លោកតែ តាំងប៉ រ ប្រធានសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា បានមានប្រសាសន៍កាលពីពេលថ្មីៗនេះថា វិស័យសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា គឺជាប្រភពទីផ្សារពលកម្មដ៏ចម្បង។

## ឧបសគ្គនៃការកង្វះខាតទុន

លោកម៉ាតធូ ហ្គាមសឺ (Matthew Gamser) ប្រធានផ្នែកសេវាកម្មប្រឹក្សាយោបល់របស់អង្គការសាជីវកម្ម ហិរញ្ញវត្ថុអន្តរជាតិប្រចាំអាស៊ីបូព៌ា និងប៉ាស៊ីហ្វិកបានឱ្យដឹងថា ទុនគឺជាប្រភពសំខាន់សម្រាប់ផលិតកម្ម និងអាជីវកម្ម។

លោកបានបន្តឱ្យដឹងទៀតដែរថា នៅពេលអាជីវកម្មមិនអាចទទួលបានហិរញ្ញវត្ថុរយៈពេលវែងបាន ពួកគេត្រូវរង់ចាំរយៈពេលជាច្រើនឆ្នាំ មុននឹងពួកគេអាចសន្សំប្រាក់បានគ្រប់គ្រាន់ ដើម្បីធ្វើហិរញ្ញប្បទានអាគារ គ្រឿងបរិក្ខារដែលធំជាងមុន និងបច្ចេកវិទ្យាប្រសើរជាងមុនដោយខ្លួនឯង។ នេះមានន័យថា ក្រុមហ៊ុនមិនបានលូតលាស់លឿនគ្រប់គ្រាន់ដើម្បីផ្តល់ការងារ ដែលកម្លាំងការងាររបស់កម្ពុជាកំពុងតែត្រូវការយ៉ាងខ្លាំងនោះឡើយ ខណៈដែលកម្ពុជា នៅក្នុងមួយឆ្នាំមានប្រជាជន ដែលគ្រប់អាយុចូលធ្វើការងារ ប្រមាណជា ២៥០០០០នាក់នោះ។

# ដ៏សំខាន់សម្រាប់ពលរដ្ឋក្រីក្រ”



Photo : V. Sambath

លោកបានឱ្យដឹងថា វិស័យសហគ្រាសធុនតូច និងមធ្យមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការធ្វើឱ្យមានការងារធ្វើដល់ប្រជាពលរដ្ឋ បង្កើនថវិកាជាតិតាមរយៈពន្ធដារ ការផ្គត់ផ្គង់សេវាកម្មផ្សេងៗ ហើយក៏ជាយន្តការមួយដ៏សំខាន់សម្រាប់ទប់ទល់នឹងការហូរចូលនូវទំនិញពីបរទេសផងដែរ ។ លោកបានបញ្ជាក់ថា: “ផ្នែកនេះ ឥឡូវ អាចផ្តល់ការងារឱ្យប្រជាពលរដ្ឋកម្ពុជាប្រមាណ ១.៤លាននាក់” ។ លោកបន្តថា បើទោះបីជាអាជីវកម្មខ្នាតតូច និងមធ្យមត្រូវបានគេចាត់ទុកថា កំពុងតែដើរតួនាទីសំខាន់នៅក្នុងការផ្តល់ប្រាក់ចំណូល និងផ្តល់ការងារធ្វើដល់ប្រជាពលរដ្ឋក៏ពិតមែន ប៉ុន្តែវិស័យនេះក៏នៅតែប្រឈមមុខនឹងបញ្ហាជាច្រើន ។ លោករៀបរាប់ថា ការលំបាកមួយចំនួន ដែលវិស័យនេះកំពុងតែជួបប្រទះនោះ គឺប្រតិបត្តិការហិរញ្ញវត្ថុ និងបញ្ហាច្បាប់ផ្សេងៗ ។ លោកបញ្ជាក់ថា: “ភាពជាសហគ្រិនរបស់យើង គឺនៅក្មេងខ្ចីណាស់ ហើយដើមទុនយើងនៅតិចបើចង់ខ្ចីធនាគារការប្រាក់ខ្ពស់ ហើយថ្លៃរត់ការក៏ថ្លៃទៀត សហគ្រាសធុនតូច និងមធ្យមនៅប្រឈមនឹងភាពស្មុគស្មាញនឹងប្រព័ន្ធពន្ធដារទៀតផងដែរ” ។

លោកតាំងប៉ រ បានឱ្យដឹងថា នៅពេលបច្ចុប្បន្នបញ្ហាប្រឈមលើផ្នែកប្រតិបត្តិការរបស់បណ្តាសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា គឺរួមមានមានផលិតភាពទាប ការចំណាយក្នុងផលិតកម្មខ្ពស់ កង្វះខាតធនធានមនុស្ស កង្វះព័ត៌មានពីទីផ្សារ និងបច្ចេកវិទ្យា ។ ម្យ៉ាងទៀតលោកបានបន្តថា សហគ្រាសជាច្រើន ត្រូវការដើមទុនដើម្បីពង្រីកប្រតិបត្តិការអាជីវកម្មតែគ្មានលទ្ធភាពនៅក្នុងការស្វែងរកឥណទានដែលមានការប្រាក់ទាប ។ ដោយឡែកនៅលើបញ្ហាច្បាប់វិញនោះគេសង្កេតឃើញថា ការចុះបញ្ជីជាសហគ្រាសក្នុងប្រព័ន្ធមាននីតិវិធីស្មុគស្មាញ និងមានតម្លៃខ្ពស់ហើយទាមទារឱ្យមានការសុំច្បាប់ និងអាជ្ញាបណ្ណច្រើន ។

បើតាមបទបង្ហាញរបស់លោកតាំងប៉ រ ដើម្បីពង្រីកអាជីវកម្មប្រភពទុន គឺមិនខ្វះទេ ។ ប៉ុន្តែអ្វីដែលខ្វះខាតនោះ គឺខ្វះខាតលទ្ធភាពក្នុងការទទួលបានឥណទានក្នុងអត្រាការប្រាក់សមរម្យ ។

លោកស្រីស្វ ផនណារី នាយករងប្រតិបត្តិនៃធនាគារអេស៊ីលីដា បានឱ្យដឹងថា បច្ចុប្បន្នដោយរួមទាំងស្ថាប័នធនាគាររបស់លោកស្រីផ្ទាល់ កម្ពុជាមានធនាគារពាណិជ្ជសរុបចំនួន២៨ ធនាគារឯកទេសចំនួន៦ ដែលមានការិយាល័យសរុបទាំងអស់ចំនួន៣៩៩កន្លែង និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន២២ ជាមួយនឹងការិយាល័យប្រតិបត្តិចំនួន ៥០៥ កន្លែងនៅទូទាំងប្រទេស ។ ប៉ុន្តែទោះបីជាយ៉ាងណា ដើម្បីធានានូវនិរន្តរភាពរបស់ខ្លួន សេវាកម្មឥណទានដែលអាចផ្តល់ជូនដល់អតិថិជនបាននោះ គឺទាល់តែផ្អែកនៅលើការវិនិច្ឆ័យផ្ទាល់ខ្លួន និងការផ្តល់ទំនុកចិត្តឱ្យគ្នាទៅវិញទៅមក ។

ម្ចាស់អាជីវកម្មខ្នាតតូចមួយរូបដែលសុំមិនបញ្ចេញអត្តសញ្ញាណ បានឱ្យដឹងថា វត្ថុទំនុកចិត្តរបស់ធនាគារទាំងអស់នោះ គឺគ្មានអ្វីក្រៅពីទ្រព្យធានាទេ ។ លោកបានឱ្យដឹងថា បើគ្មានអ្វីដាក់បញ្ចាំដែលមានតម្លៃខ្ពស់លើសពីទំហំសាច់ប្រាក់ដែលយើងចង់ខ្ចី ពិរទៅបីដងទេកុំរំពឹងថាគេនឹងផ្តល់ទុនឱ្យ ហើយអត្រាការប្រាក់វិញទៀតសោតក៏ខ្ពស់ ។

អ្វីដែលអ្នកជំនាញការលើកឡើងនោះគឺមិនខុសនោះទេ ហើយមួយចំនួនបានកើតឡើងចំពោះអ្នកស្រីជា រ៉ា ជាបន្តបន្ទាប់ ។

អ្នកស្រីជា រ៉ា បានឱ្យដឹងថា ដោយសារតែបញ្ហាសុខភាព អ្នកស្រីមានការហត់នឿយក្នុងការរុញរទេះនេះ ហើយចង់បាននូវឥណទានខ្លះដើម្បីយកទៅទិញជាម៉ូតូកង់បី និងពង្រីករបរ ។ អ្នកស្រីបានបញ្ជាក់ថា : “ខ្ញុំគិតថាខ្ចីគេ ៣០០០ដុល្លារយកទៅទិញម៉ូតូ និងឱ្យគេច្នៃជំនួសរទេះ ហើយបន្ថែមរបស់លក់ ប៉ុន្តែគេទារឱ្យយកផ្ទះទៅបញ្ចាំ ខ្ញុំខ្លាចក៏ខ្ចិលទៅ ។ ចាំមើលសន្សំខ្លួនឯង មួយឆ្នាំ ពីរឆ្នាំទៀត” ។ អ្នកស្រីបានឱ្យដឹងទៀតថា ជុំវិញបញ្ហាច្បាប់វិញ អ្នកស្រីបានជួបប្រទះផងដែរ ។ អ្នកស្រីបានឱ្យដឹងថាជារឿយៗតែងតែជួបនឹងអាជ្ញាធរទារលិខិតនេះលិខិតនោះគាត់មិនយល់ក៏បង់លុយឱ្យគេទៅ ។

អ្នកស្រីបញ្ជាក់ថា: “ខ្ញុំតែងតែជួបអាជ្ញាធរតាញ៉ីហ្នឹងគេទារនេះ ទារនោះ ខ្ញុំមិនយល់ចេះតែបង់លុយឱ្យគេទៅ ជូន៥០០០រៀល ជូន ១០០០០រៀល ហើយជូន១៥០០០ រៀល តែមិនជារាល់ថ្ងៃទេ” ។

## ស្ថិតិសហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា

លោកស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានឱ្យដឹងថា នៅទូទាំងប្រទេសកម្ពុជាមាន សហគ្រាសអាជីវកម្មទាំងអស់ទាំងចុះបញ្ជី និងមិនចុះបញ្ជីសរុបចំនួន ៣៧៥០៩៥ នៅក្នុងនោះ ជាង៩០% នៃសហគ្រាសទាំងអស់នោះ គឺប្រើប្រាស់ថវិកាផ្ទាល់ខ្លួន ឬកម្ចីពីគ្រួសារ និងមិត្តភក្តិដើម្បីចាប់ផ្តើមអាជីវកម្ម និងជំរុញដំណើរការអាជីវកម្ម។

យោងទៅតាមតួលេខរបស់សមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា បានឱ្យដឹងថា រហូតមកដល់ពេលនេះ បណ្តាសហគ្រាសខ្នាតតូច និងមធ្យមដែលផ្តល់ការងារធ្វើដល់មនុស្សពី១នាក់ទៅដល់ ១០នាក់ គឺមានចំនួន ៣០៧០០០ សហគ្រាស ហើយសហគ្រាស់ដែលផ្តល់ការងារដល់មនុស្សធ្វើការពី ១១នាក់ ទៅដល់១០០នាក់ មានចំនួន ១៣១២៣សហគ្រាស។ សរុបទៅកម្លាំងពលកម្មដែលកំពុងតែបម្រើការនៅក្នុងផ្នែកនេះ គឺមានចំនួនប្រមាណជា ១,៤លាននាក់។

# ដំណើរទស្សនកិច្ចលើកដំបូងរបស់លោក អគ្គរាជទូតសម្ដេចប៉ាបនៅប្រទេសកម្ពុជា

**លី សុវណ្ណា**

លោកជីអូ វ៉ាន់នី អាល់នីឡូ អគ្គរាជទូតថ្មីរបស់សម្ដេចប៉ាបបេណេឌីកតូទី១៦ ប្រចាំព្រះរាជាណាចក្រកម្ពុជាបានមកបំពេញទស្សនកិច្ចរបស់លោកជាលើកដំបូងនៅព្រះរាជាណាចក្រកម្ពុជា កាលពីដើមខែមករា ឆ្នាំ២០១១ កន្លងទៅនេះ ។

នៅក្នុងដំណើរទស្សនកិច្ចនេះ លោកអគ្គរាជទូតបានចូលថ្វាយបង្គំគាល់ និងក៏ថ្វាយសារតាំងចំពោះព្រះករុណា ព្រះបាទ ព្រះបរមនាថ សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងបានចូលជួបជាមួយមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលផងដែរ ។

នៅក្នុងដំណើរទស្សនកិច្ចនេះ លោកក៏បានចូលរួមអង្គសិក្ខានៃសាលាយុវជននៅភូមិភាគកាតូលិកភ្នំពេញ និងបានសួរសុខទុក្ខក្រុមព្រះសហគមន៍កាតូលិកមួយចំនួនផងដែរ ។

នៅក្នុងពិធីលៀងសាយភោជនៅឯនិវេសនដ្ឋានរបស់លោកអភិបាលសុខកុមារ អូលីវីយេ ឆ្មីតអីស្លែរ នៃព្រះសហគមន៍ភូមិភ្នំពេញ លោកអគ្គរាជទូតក៏បានមានប្រសាសន៍ទៅកាន់តំណាងនៃសាសនទូតអង្គការ ក្រុមគ្រួសារបព្វជិតបព្វជិតា គណៈកម្មការតំណាងព្រះសហគមន៍នានា ក្នុងភូមិភាគប្រមាណជាង៣០០នាក់ ថា លោកសូមអរព្រះគុណព្រះជាម្ចាស់ និងសូមកោតសរសើរព្រះសហគមន៍កាតូលិក នៅប្រទេសកម្ពុជាដែលមានសកម្មភាព និងជីវិតយ៉ាងរស់រវើកដែលពោរពេញទៅដោយជំនឿយ៉ាងមាំមួន ។ លោកបានលើកទឹកចិត្តដល់អ្នកចូលរួមទាំងអស់ក៏ជាដូចជាគ្រីស្តបរិស័ទនៅកម្ពុជាទាំងមូលឱ្យបន្តបេសកកម្មសម្រាប់សេចក្ដីស្រឡាញ់របស់ព្រះយេស៊ូបន្តទៀត ។

នៅខណៈនោះដែរ លោកអភិបាលអូលីវីយេ ក៏បានប្រគល់ជូនលោកអគ្គរាជទូតនូវថវិកាដែលព្រះសហគមន៍នៅកម្ពុជា ប្រមូលបានក្នុងទិវាបេសកកម្មពិភពលោកដើម្បីជាសញ្ញានៃការចូលរួមយ៉ាងជិតស្និទ្ធរវាងព្រះសហគមន៍សកល និងព្រះសហគមន៍កាតូលិកនៅកម្ពុជា ។



Photo : Pou Tong

លោកអគ្គរាជទូតមានគម្រោងនឹងមកបំពេញទស្សនកិច្ចនៅកម្ពុជាម្ដងទៀតនៅពាក់កណ្ដាលខែកុម្ភៈ ឆ្នាំ២០១១ខាងមុខនេះ ។

សូមបញ្ជាក់ថាលោកអគ្គរាជទូតជីអូវ៉ាន់នីអាល់នីឡូប្រសូតនាថ្ងៃទី៥ មករា ឆ្នាំ១៩៥៥នៅប្រទេសអ៊ីតាលី ។ លោកទទួលការតែងតាំងជាអគ្គរាជទូតនៃបុរីវ៉ាទីកង់ប្រចាំព្រះរាជាណាចក្រកម្ពុជាកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១០ ។

---

## គ្រឿងឧបភោគបរិភោគស្មើនឹងទឹកប្រាក់ ១០០០ដុល្លារចែកជូនដល់ ៦០គ្រួសារ

គ្រឿងឧបភោគបរិភោគតម្លៃ១០០០ដុល្លារ ត្រូវបានធ្វើការចែកជូនដល់គ្រួសារខ្វះខាតចំនួន ៦០ គ្រួសារដែលក្នុងនោះមកពីសង្កាត់បឹងត្របែក ២០ គ្រួសារ សង្កាត់ក្បាលទំនប់បឹងទំពុន ៣០គ្រួសារ និងសង្កាត់បឹងទំពុន ១០គ្រួសារផ្សេងទៀត កាលពីថ្ងៃទី២២ មករា នៅព្រះវិហារបឹងទំពុន។

លោកឡើន សំណាង គណៈកម្មការព្រះវិហារបឹងទំពុន និងអ្នកទទួលខុសត្រូវកិច្ចការនេះនិយាយថា ការចែកជូននូវគ្រឿងឧបភោគបរិភោគដល់៦០គ្រួសារនេះ គឺធ្វើឡើងនាឱកាសអបអរសាទរបុណ្យព្រះយេស៊ូប្រសូត ដែលព្រះវិហារបឹងទំពុនតែងតែធ្វើ ២ដងក្នុងមួយឆ្នាំ គឺនារដូវបុណ្យព្រះយេស៊ូប្រសូត និងបុណ្យចម្លង ហើយនេះជាការចូលរួមវិភាគទានពីបងប្អូនគ្រីស្តបរិស័ទ។ លោកក៏បានបន្ថែមថា ក្រៅពីជួយគ្រួសារខ្វះខាត ព្រះវិហារបឹងទំពុន ក៏មានផ្ដល់វគ្គជំនាញសិក្សាជាងកាត់ដេរ និងផ្នែកជាងទង ព្រមទាំងការសិក្សាថ្នាក់មត្តេយ្យដល់ប្អូនៗកុមារចាប់ពីអាយុ៣-៥ឆ្នាំផងដែរ។ **សុខន**

---

## មូលនិធិកុមារដុនបូស្កូ ចែកអំណោយដល់កុមារ

កុមារកំព្រា កុមារទុរគតិ កុមារបោះបង់ការសិក្សា និងកុមារដែលរស់នៅជាមួយឪពុកម្ដាយធ្វើការជាមួយកម្មករ មានជីវភាពក្រីក្រលំបាក និងមិនបានទៅសាលារៀនប្រមាណ ២៥០នាក់ បានទទួលអំណោយពីមូលនិធិកុមារដុនបូស្កូ ក្នុងខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩-២០ មករា មុននេះ ។

កញ្ញាចាន់ ម៉ាឡា អ្នកគ្រប់គ្រងកម្មវិធីមូលនិធិកុមារដុនបូស្កូប្រចាំនៅខេត្តព្រះសីហនុ បានឱ្យដឹងថា កុមារទាំងនោះ កំពុងសិក្សានៅសាលារដ្ឋនានាពីថ្នាក់ទី១រហូតដល់ថ្នាក់ទី១២ ក្នុងខេត្តព្រះសីហនុដែលទទួលបានការឧបត្ថម្ភគាំទ្រពីមូលនិធិកុមារដុនបូស្កូ ហើយអំណោយដែលបានផ្ដល់ជូនកុមារទាំងនោះរួមមានសម្ភារៈសិក្សា សាប៊ូដុសខ្លួន សាប៊ូបោកខោអាវ ថ្នាំដុសធ្មេញ ត្រីខ មី ទឹកដោះគោ ស្ករ ស និងថវិកាមួយចំនួន ។

កញ្ញាចាន់ ម៉ាឡា បានបញ្ជាក់ដែរថា កុមារទាំងនេះទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែខុសៗ ពីគ្នាទៅតាមថ្នាក់របស់ពួកគេ ។ ដោយពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ ទទួលបាន១៥០០០រៀល ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ ទទួលបាន២០០០០រៀល ។ ចំណែកពីថ្នាក់ទី១០ ដល់ទី១២ ម្នាក់ៗ ទទួល ២៥០០០រៀល ។

កញ្ញាចាន់ ម៉ាឡា បានបញ្ជាក់ដែរថា មូលនិធិកុមារដុនបូស្កូខេត្តព្រះសីហនុ ចាប់ផ្ដើមតាំងពីឆ្នាំ១៩៩៧ ក្នុងគោលបំណងឱ្យកុមារា ដែលបានបោះបង់ការសិក្សាកុមារក្រីក្រ ឱ្យបានចូលរៀនសូត្រនៅតាមសាលា និងដើម្បីផ្ដល់ឱកាសដល់ក្មេងៗទាំងនោះទទួលបានចំណេះដឹង និងជំនាញផ្សេងៗជាដើម ។

កញ្ញាចាន់ ម៉ាឡា ក៏បានរៀបរាប់ឱ្យដឹងទៀតដែរថា ក្រោយពីបញ្ចប់ការសិក្សានៅថ្នាក់ទី១២ កុមារទាំងនោះ គឺអាចបន្តការសិក្សាជំនាញ លុះត្រាប្រឡងជាប់ និងឆ្លងកាត់បទសម្ភាសន៍ ដែលអាចបញ្ជាក់ថាពិតជាមានជីវភាពក្រីក្រប្រាកដមែន ។ ជំនាញទាំងឡាយនោះគឺរួមមានជំនាញសណ្ឋាគារ ជាងឡាន អគ្គីសនី លេខាធិការទំនាក់ទំនងសាធារណៈ និងជាងគ្រឿង ក្រោយការវាយតម្លៃការសិក្សា ។

ជំនួយសម្រាប់កម្មវិធីនេះគឺបានមកពីប្រទេសអាមេរិក បារាំង អ៊ីតាលី និងហូឡង់ជាដើម ។

**ជុង យ៉េត**

# ល្បែងជាវិធីសាស្ត្រក្នុងការបង្រៀនគណិតវិទ្យា



Photo : An Rithyrath

នាពេលបច្ចុប្បន្ននេះ នៅប្រទេសកម្ពុជា គឺមានការពង្រឹងនូវផ្នែកអប់រំយ៉ាងខ្លាំង ដើម្បីឱ្យមានការកើនឡើងនូវធនធានមនុស្ស ។

សិក្ខាសាលាដែលណែនាំដោយក្រុមគ្រូបង្រៀនមកពីប្រទេសអូស្ត្រាលីស្តីអំពីការអប់រំផ្នែកគណិតវិទ្យាដល់ លោកគ្រូ អ្នកគ្រូនៅកម្រិតបឋមសិក្សា បានប្រព្រឹត្តនៅព្រះសហគមន៍កាតូលិកបាត់ដំបង កាលពីថ្ងៃទី១៣ដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១១ កន្លងទៅថ្មីៗនេះ ។ កញ្ញាកិរិន ធារ៉ា ជាអ្នកសម្របសម្រួលសិក្ខាសាលានេះ បន្តថា យើងក៏បានបង្ហាត់ពួកគាត់អំពីល្បែងតែ ជាវិធីសាស្ត្របង្រៀននូវក្បួនក្នុងការគិតលេខពីចំនួនគត់ ។ កញ្ញាបន្តថា : "ការប្រើប្រាស់សម្ភារៈ សម្រាប់ធ្វើជាល្បែងផ្នែកគណិតវិទ្យាក្នុងការបង្រៀនពេលម៉ោងសិក្សាជាលក្ខណៈពិសេសក្នុងអង្គសិក្ខាសាលា ដែលចង់ឱ្យគ្រូៗ មានវិធីក្នុងការបង្រៀនឱ្យបានល្អ និងមិនធ្វើឱ្យសិស្សមានអារម្មណ៍ស្អុតស្អាញក្នុងការរៀនសូត្រ" ។

ធារ៉ា និយាយទៀតថា : "ដើម្បីឱ្យមានប្រសិទ្ធភាពយើងក៏បានតាមដានលោកគ្រូ អ្នកគ្រូ ក្នុងការបង្រៀនសិស្ស ជារៀងរាល់ខែ ថាតើ គាត់បានអនុវត្តតាមអ្វីបានបង្រៀន ឬយ៉ាងណា?" ។

សិក្ខាសាលានេះមានការចូលរួមពីលោកគ្រូអ្នកគ្រូ ១១៥នាក់ ដែលមកពីសាលាបឋមផ្សេងៗដូចជា សាលាព្រៃធំ ចំណោម ពោធិ៍សាត់ សាលាដុនបូស្កូ សាលាបងស្រីស៊ីស៊ីល សាលាអូអឺអេហ្វ (មោង) សាលាបោះរូង (រុក្ខគិរី) និងសាលាបឋមរតនៈ ។

អ្នកគ្រូគឹម សុភារី គ្រូបង្រៀននៅសាលាបឋមសិក្សារតនៈ ថ្នាក់ទី១ ក៏បានបន្ថែមទៀតថា : "អង្គសិក្ខាសាលានេះបានបង្រៀនឱ្យគាត់ ចេះកាត់បិតក្រដាសដើម្បីធ្វើជាល្បែងសម្រាប់កូនសិស្សដែរ" ។

**អាន ឬទ្ធីរដ្ឋ**

# ស្វែងយល់អត្ថន័យព្រះសហគមន៍កាតូលិកគឺស្វែងយល់ជំនឿខ្លួន



Photo : V. Samphy

លោកបូជាចារ្យប៊ុយណូ កូសម៍ អ្នកទទួលខុសត្រូវព្រះសហគមន៍សន្តយ៉ូសែប ហៅផ្សារតូច នៅរាជធានីភ្នំពេញ បានមានប្រសាសន៍ថា ដើម្បីឱ្យបងប្អូនគ្រីស្តបរិស័ទ និងអ្នកដែលកំពុងស្វែងយល់អំពីព្រះសហគមន៍កាតូលិកយល់កាន់តែច្បាស់អំពីជំនឿរបស់ខ្លួន និងមានទំនាក់ទំនងល្អនឹងគ្នាចាំបាច់គ្រីស្តបរិស័ទគួរមានការស្វែងយល់បន្ថែមអំពីអត្ថន័យនៃព្រះសហគមន៍កាតូលិក ។

សិក្ខាសាលាលើកទី១ ស្តីអំពីអត្ថន័យនៃព្រះសហគមន៍កាតូលិក ដែលប្រព្រឹត្តនៅថ្ងៃទី២៣ ខែមករានេះ គឺជាស្ពានចម្លង១ ដែលនឹងនាំបងប្អូនឱ្យស្គាល់គ្នាគេទៅវិញទៅមក និងមានទំនាក់ទំនងល្អក្រៅពីការមកចូលរួមកម្មវិធីអភិបូជាថ្ងៃអាទិត្យ ។

លោកបូជាចារ្យរូបនេះ ពន្យល់យ៉ាងនេះថា អ្វីដែលព្រះសហគមន៍មើលឃើញ គឺបងប្អូនភាគច្រើនមិនសូវមានពេលសំណេះសំណាល និងចែករំលែកនូវបទពិសោធន៍នៃជំនឿសម្រាប់គ្នា ទោះបីជាអ្នកបម្រើការងាររួមគ្នាក្នុងព្រះ សហគមន៍ ។

សិក្ខាសាលានេះ ប្រព្រឹត្តិចាប់ពីម៉ោង ១០ព្រឹក ដល់ម៉ោង៣រសៀល ដែលមានកម្មវិធីដូចជា ទី១ ការបង្ហាញខ្លួន ទី២ មូលហេតុនៃអង្គសិក្ខាសាលា ។ ទី៣ អត្ថន័យព្រះសហគមន៍ ។ ទី៤ ផ្តល់សក្ខីភាពជំនឿអត្ថន័យព្រះសហគមន៍តាមព្រះគម្ពីរ... ។

**សុខន**

# ទីស្នាក់បណ្តោះអាសន្នថ្មីរបស់យុវជនដើម្បីបន្តការសិក្សានៅសាលាទុតិយភូមិ

អគារមួយខ្នងទំហំ៨គុណ៩ម៉ែត្រ ពីឈើត្រូវបានស្ថាបនាឡើងក្នុងទិសដៅផ្តល់ទីស្នាក់អាស្រ័យសម្រាប់សិស្សានុ-សិស្សដែលមានទីលំនៅឆ្ងាយពីសាលារៀន និងចង់បន្តការសិក្សារហូតដល់ថ្នាក់ទី១២។

លោកបូជាចារ្យអ៊ីវ៉ាន់ អ្នកទទួលខុសត្រូវព្រះសហគមន៍ក្ពុលលើនិយាយថា សាលានៅភូមិទ្រា និងភូមិក្ពុលលើមានត្រឹមតែថ្នាក់ទី៩។ សិស្សដែលរស់នៅក្នុងភូមិទាំងពីរចាំបាច់ត្រូវធ្វើដំណើរទៅសិក្សានៅស្រុកស្ទឹងត្រង់ ដែលមានវិទ្យាល័យតែមួយដើម្បីប្រេបយកចំណេះដឹង។ លោកបន្តថា : "អាគារនេះនឹងផ្តល់ទីសមរម្យដល់សិស្សសាលា ឱ្យសម្រាក និងបរិភោគអាហារថ្ងៃត្រង់រួមគ្នាមុនពេលបន្តម៉ោង សិក្សានៅពេលរសៀល"។

អគារថ្មីស្រឡាងកំពុងសាងសង់នេះ មានឈ្មោះថា "មណ្ឌលយុវជនព្រះសហគមន៍កាតូលិកស្ទឹងត្រង់" ដែលសាងសង់នៅស្រុកស្ទឹងត្រង់ខេត្តកំពង់ចាម។

លោកបូជាចារ្យរូបនេះថា ត្បិតសិស្សសាលាភាគច្រើនជួបនឹងការលំបាកក្នុងការធ្វើដំណើរពីគេហដ្ឋានរបស់ខ្លួនទៅសាលាទាំងផ្លូវគោក និងផ្លូវទឹក ម្យ៉ាងទៀតត្រូវចំណាយពេលវេលាយ៉ាងហោចណាស់ ១ ម៉ោង ឬក្រួមនឹងកត្តាជីវភាពខ្វះខាត ហេតុនេះទើបមានប្អូនៗមួយចំនួនធំបានបោះបង់ចោលការសិក្សារបស់ខ្លួនទាំងប្រុសទាំងស្រី ហើយត្រឡប់ទៅជារូបភាពចំណាកស្រុកដើម្បីស្វែងរកការងារនៅ ប៉ោយប៉ែតជំនួសការសិក្សា។ ទីស្នាក់នេះបង្កើតឡើងដើម្បីជួយដល់ពួកគេ។ ទីស្នាក់នេះក៏ទទួលការឧបត្ថម្ភពីក្រុមអង្គការបារាំងដែលមានឈ្មោះ Coup de pouce ដែលជាអំណោយសប្បុរសជនលើកទី៤ ចំពោះក្រុមដែលតែងតែមានសកម្មភាពរាល់ឆ្នាំក្នុងការជួយសាងសង់ផ្ទះដល់ប្រជាជនក្រីក្រ។

គួរបញ្ជាក់ថា ទីស្នាក់នេះនឹងផ្តល់កន្លែងអាស្រ័យសិក្សាដល់យុវជនកាតូលិកចំនួន ៥៥នាក់ និងមិនមែនកាតូលិក ៧នាក់ផ្សេងទៀតឱ្យសម្រាក និងញ៉ាំអាហារថ្ងៃត្រង់ដែលផ្តល់ជូនពីព្រះសហគមន៍កាតូលិក និងជូនការសិក្សាបន្ថែមលើផ្នែកគណិតវិទ្យា។

**សុខន**

# ព្រះសហគមន៍ភូមិភាគបាត់ដំបង រំពឹងថា ទទួលបានផលដូចឆ្នាំមុន

**ខាន់ ភីរម្យ**

ក្រុមស្រែភូមិភាគនៃព្រះសហគមន៍ភូមិភាគបាត់ដំបង រំពឹងថា នឹងប្រមូលទិន្នផលស្រូវប្រហាក់ប្រហែលគ្នានឹងឆ្នាំមុន ដើម្បីទុកបម្រើការងារ នៅក្នុងព្រះសហគមន៍ ខណៈដែលព្រះសហគមន៍ មួយកំពុងតែសម្តែងនូវការព្រួយបារម្ភ ខណៈដែលផលស្រូវរបស់ពួកគេមានការធ្លាក់ចុះ ដោយសារបញ្ហាបាតុភូតធម្មជាតិកាលពីរដូវបង្កបង្កើនផល ។

លោកច្រុចសាវ៉ែន ដែលជាលេខាព្រះសហគមន៍ចំណោមនៅក្នុងភូមិភាគបាត់ដំបង មានប្រសាសន៍ថា ទិន្នផលនៅចំណោម ឆ្នាំនេះធ្លាក់ចុះដោយសារតែទឹកជំនន់។ លោកបានបញ្ជាក់ថា: "ឆ្នាំទៅយើងទទួលបានប្រមាណជា ២,៥តោន ក្នុងមួយហិចតា ឆ្នាំនេះ មើលទៅអាចបានត្រឹមតែ ១,៥ តោនទេនៅក្នុងមួយហិចតា ដោយសារស្រូវភាគច្រើនខូចដោយកាលលិចទឹក" ។

តាមប្រសាសន៍របស់លោកសាវ៉ែន ទិន្នផលស្រូវដែលព្រះសហគមន៍ចំណោមផលិតបាន គឺសម្រាប់ជួយដល់កិច្ចការមនុស្សធម៌ផ្សេងៗ ក្នុងព្រះសហគមន៍។ ប៉ុន្តែដោយសារការធ្លាក់ចុះទិន្នផល លោកក៏បានសម្តែងនូវការព្រួយបារម្ភដែរ ចំពោះសកម្មភាពមនុស្សធម៌ដែលឆ្នាំមុនធ្លាប់ពឹងទៅលើធនធានស្រូវនេះ។ លោកបានបញ្ជាក់ដែរថា ស្រូវរបស់យើងមិនត្រឹមតែទុកសម្រាប់បម្រើកិច្ចការមនុស្សធម៌ ក្នុងព្រះសហគមន៍តែប៉ុណ្ណោះទេ តែយើងត្រូវបែងចែកសម្រាប់ជួយដល់ជនក្រីក្រ ក្នុងព្រះសហគមន៍ផ្សេងៗដូចជាបាត់ដំបង និងកំពង់ធំផងដែរ។

គ្រោះមហន្តរាយធម្មជាតិនេះគឺជាសេចក្តីបារម្ភមួយហើយសម្រាប់ព្រះសហគមន៍ចំណោម។ ប៉ុន្តែក្រៅគ្រោះមហន្តរាយនេះ បញ្ហាតម្លៃស្រូវក៏ជាក្តីកង្វល់មួយទៀតផងដែរ សម្រាប់ព្រះសហគមន៍ចំណោម និងប្រជាកសិករផ្សេងៗទៀត នៅក្នុងសហគមន៍ចំណោមនេះទាំងមូល ។

លោកពេត្រូ កូស៊ីមែស៊ី បូជាចារ្យព្រះសហគមន៍ចំណោមបានមានប្រសាសន៍ថា តម្លៃដ៏ថោករបស់ស្រូវនៅក្នុងឆ្នាំនេះក៏ជាក្តីកង្វល់មួយដែរ។ លោកបានមានប្រសាសន៍ថា ស្រែនៅចំណោមអាចផ្តល់ផលស្រូវប្រមាណជា ៣0% ប៉ុណ្ណោះ។ លោកបានមានប្រសាសន៍ទៀតថា កសិករនៅទីនោះកំពុងតែជួបការលំបាកដោយសារស្រូវផលិតបានតិច ហើយតម្លៃផលស្រូវថោកទៀត។ លោកក៏បញ្ជាក់ថា : "កសិករខ្លះអាចជាប់បំណុលដោយសារពួកគេជំពាក់គេយកលុយមកទិញពូជជី និងសោហ៊ុយផ្សេងៗ" ។

បើតាមប្រសាសន៍របស់លោកបូជាចារ្យពេត្រូ តម្លៃស្រូវនៅបាត់ដំបងបច្ចុប្បន្ននេះ បានថយចុះពីមួយតោន ១0000បាត មកនៅត្រឹមតែពី ៦000 ទៅ ៧000បាត តែប៉ុណ្ណោះ។

នៅជុំវិញបញ្ហានេះ កញ្ញាទុំ វ៉ាន់ណើ ជំនួយការប្រធានក្រុមស្រែនៅភូមិភាគបាត់ដំបង បានទទួលស្គាល់ថា ឆ្នាំនេះដោយសារតែធម្មជាតិ សហគមន៍ខ្លះផលិតបានច្រើន។ ខ្លះក៏ធ្លាក់ចុះ។ ប៉ុន្តែយើងនៅមិនទាន់បានបូកសរុបនៅឡើយទេ។ កញ្ញាក៏បានបញ្ជាក់ថា : "យើងរំពឹងថា ទិន្នផលសរុប នឹងទទួលបានដូចឆ្នាំមុន" ។

ក្រុមស្រែនៅភូមិភាគព្រះសហគមន៍បាត់ដំបងមានស្រែទាំងអស់ចំនួន ២១៥ហិចតា ក្នុងនោះមាន ៤៨ហិចតានៅព្រះសហគមន៍ចំណោម ៧២ហិចតានៅទំពូង ៨,៥ហិចតានៅខ្នាចរមាស នៅបាត់ដំបងមាន ៨,៥ហិចតា និងនៅវាលទ្រាចំនួន ៨ហិចតា ដោយទទួលបានផលសុរបប្រមាណជា ២៣៩តោន នៅក្នុងនោះទុកចំនួន ១៥៩តោន សម្រាប់កិច្ចការផ្សេងៗនៅក្នុងព្រះសហគមន៍ ហើយនៅសល់ចំនួនប្រមាណជា៨0តោនសម្រាប់លក់ដើម្បីយកទូទាត់ថ្លៃប្រេង និងសោហ៊ុយផ្សេងៗ ក្នុងដំណើរការក្រុមស្រែ និងកិច្ចការមនុសធម៌ព្រះសហគមន៍ ។



Photo : P. Samphy

## ជីវិតខ្ញុំ

# "ខ្ញុំចង់ឃើញនោះ គឺព្រះសហគមន៍មានភាពជាធ្លុងតែមួយ"

**អ៊ឹម សុខន**

លោកបូជាចារ្យឡេវ៉ាន់ទីន មានកំណើតនៅឆ្នាំ ១៩៤១ នៅស្រុកក្បៀងវ៉ា ប្រទេសវៀតណាម ។ បច្ចុប្បន្ន លោក ទទួលខុសត្រូវព្រះសហគមន៍ចំនួន ១៣កន្លែង នៅភូមិភាគភ្នំពេញ ដែលភាគច្រើនជាគ្រីស្តបរិស័ទដើមកំណើត វៀតណាម ។

លោកបូជាចារ្យឡេវ៉ាន់ទីន មានប្រសាសន៍អំពីដំណើរជីវិតក្នុងអតីតថា ស្វែងរកនូវសេរីភាពដើម្បីជីវិតរស់នៅ ជាមូលហេតុតែមួយគត់ ដែលនាំខ្ញុំឱ្យស្គាល់ព្រះសហគមន៍នៅប្រទេសកម្ពុជា ។

នៅឆ្នាំ១៩៧៥ លោកជាជនភៀសខ្លួនម្នាក់ដែលចង់ស្វែងរកសេរីភាពជីវិត ។ លោកមានប្រសាសន៍ថា មិនថាតែក្នុងប្រទេសកម្ពុជាដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម សូម្បីតែប្រជាពលរដ្ឋវៀតណាមខាងត្បូង ក៏ទទួលរងការគាបសង្កត់ពីអ្នកគ្រប់គ្រងដែរ ។ហេតុដូច្នេះមានបងប្អូនវៀតណាមមួយចំនួនធំគិតចង់ទៅរស់នៅប្រទេសទី៣ ។

នៅឆ្នាំ១៩៨៩ លោកសម្រេចចិត្តភៀសខ្លួនទៅកាន់ព្រំដែនកម្ពុជា-ថៃ គឺកាត់តាមខេត្តកោះកុង ។ ប៉ុន្តែការរត់គេចនោះ ពុំទទួលបានជោគជ័យឡើយ និងផ្ទុយទៅវិញ លោកក៏ត្រូវបានពលទាហានខ្មែរចាប់ឃុំឃាំង ចំនួនពីរដង ក្នុងនាមជាពលរដ្ឋវៀតណាមដែលលួចឆ្លងដែននៅខេត្តកោះកុងដើម្បីធ្វើដំណើរឆ្ពោះទៅប្រទេសថៃក្នុងគោលបំណងទៅប្រទេសអាមេរិក ឬអូស្ត្រាលី ។ លោកបន្តថា: "នៅដែលខ្ញុំបម្រុងនឹងឆ្លងដែនពីកម្ពុជាទៅថៃគឺត្រូវបានចាប់ឃុំ អស់រយៈពេលជាង២ខែ ហើយលុយកាក់ដែលខ្ញុំមានទាំងប៉ុន្មាន ក៏ត្រូវពួកគេរឹបអូសយករួចទើបបញ្ជូនឱ្យទៅស្រុកកំណើតវិញ" ។

ក្នុងសភាពជីវិតដែលពឹងផ្អែកលើព្រះជាម្ចាស់ រូបលោកបានស្គាល់បងស្រីម្នាក់នៃក្រុមគ្រួសារបងស្រីប្រ៊ូវីដង់ នៅព្រះសហគមន៍ចំប៉ា ស្របពេលដែលលោកកំពុងធ្វើដំណើរទៅស្រុករបស់ខ្លួនវិញដែលពេលនោះ លោកក៏បានរស់នៅ និងធ្វើការក្នុងនាមជាអ្នកស្ម័គ្រចិត្ត ។ លោកមានប្រសាសន៍បន្តថា: "ខ្ញុំក៏បានធ្វើការជាអ្នកបកប្រែ ឱ្យលោកឪពុកថូម៉ាស ឡៀន ម៉ាលី ជនជាតិអាម៉េរិក នៃក្រុមគ្រួសារម៉ារីណុលរហូតដល់ឆ្នាំ១៩៩៧" ។

បើទោះជាកិច្ចការបម្រើការងារព្រះសហគមន៍ជួបលើឧបសគ្គនៅពេលខ្លះយ៉ាងណា ក៏លោកមានប្រសាសន៍ដោយរំពឹងថា: "អ្វីដែលខ្ញុំចង់ឃើញនោះ គឺព្រះសហគមន៍មានភាពរួមជាធ្លុងតែមួយ មិនថាមានបងប្អូនគ្រីស្តបរិស័ទខ្មែរ វៀតណាមក្តី និងអ្វីដែលដែលជាគន្លឹះនាំឱ្យមានក្រុមគ្រួសារតែមួយ គឺភាសានិងការបើកចិត្តគំនិតទទួលគ្នាជាបងប្អូន" ។



Photo : Sokhorn

## សម្តេចប៉ាបជំរុញឱ្យយកចិត្តទុកដាក់លើបច្ចេកវិទ្យាទូរគមនាគមន៍ដើម្បីផ្សព្វផ្សាយដំណឹងល្អ

ដើម្បីអបអរដល់ថ្ងៃខួបលើកទី៤៥ នៃទិវាទំនាក់ទំនងពិភពលោក ដែលនឹងប្រារព្ធធ្វើឡើងនៅក្នុងខែមិថុនាខាងមុខនេះ សម្តេចប៉ាបបេណេឌីកទី១៦ បានស្នើសុំឱ្យព្រះសហគមន៍យកចិត្តទុកដាក់លើការផ្សព្វផ្សាយដំណឹងល្អតាមរយៈបច្ចេកវិទ្យាទូរគមនាគមន៍។

ក្នុងសារលិខិតមួយដែលបានចេញកាលពីថ្ងៃទី២៤ ខែមករាមុននេះ សម្តេចប៉ាបមានប្រសាសន៍ថា ប្រព័ន្ធអ៊ីនធឺណិត ហើយនិងប្រព័ន្ធទំនាក់ទំនងឌីជីថលទាំងអស់ជាចរិតលក្ខណៈបាតុភូតរបស់សង្គមមនុស្សនាជំនាន់នេះ។

សម្តេចបន្ថែមទៀតថា អ៊ីនធឺណិតគឺជាបណ្តាញទំនាក់ទំនងមួយដ៏ចម្បងនៅលើពិភពលោក ហើយអ្វីដែលរឹតតែជ្រាលជ្រៅទៅទៀតនោះ គឺថាអ៊ីនធឺណិតជាការឆ្លុះបញ្ចាំងនូវការវិវត្តន៍នៃឧស្សាហកម្មដែលនាំមកនូវការផ្លាស់ប្តូរដ៏ជ្រាលជ្រៅនៅក្នុងសង្គម។

សម្តេចប៉ាបគូសបញ្ជាក់ថា : "ជើងមេឃថ្មីបានចាប់ផ្តើមបើកហើយក៏ជាពេលដែលយើងត្រូវរិះគិតអំពីសារៈសំខាន់អំពីទំនាក់ទំនងនៅក្នុងយុគសម័យឌីជីថល"។

សម្តេចមានប្រសាសន៍បន្តថា យុវជនគេបានឆ្លងកាត់នូវបទពិសោធន៍នៃការផ្លាស់ប្តូរនេះ ជាមួយនឹងបញ្ហាប្រឈមសេចក្តីបារម្ភ និងគំនិតច្នៃប្រឌិតផ្សេងៗនៅក្នុងបទពិសោធន៍នៃជីវិតរបស់ពួកគេ។

បើទោះជាសម្តេចប៉ាបបានជំរុញនឹងលើកទឹកចិត្តព្រះសហគមន៍ឱ្យប្រើប្រាស់បច្ចេកវិទ្យាទូរគមនាគមន៍ទំនើបនៅក្នុងការកសាងនូវបណ្តាញសង្គម និងផ្សព្វផ្សាយដំណឹងល្អក៏ដោយ ប៉ុន្តែសម្តេចប៉ាបបានស្នើសុំឱ្យព្រះសហគមន៍មានការយកចិត្តទុកដាក់លើការបង្ការបញ្ហាប្រថុយប្រថានផ្សេងៗដែលអាចកើតមានឡើង។

សម្តេចប៉ាបបញ្ជាក់ថា បច្ចេកវិទ្យាថ្មីៗអនុញ្ញាតឱ្យមនុស្សជួបគ្នានៅក្រៅការកំណត់ព្រំដែននៃវប្បធម៌របស់ពួកគេដោយបង្កើតឡើងនូវមធ្យោបាយថ្មីដែលគេហៅថា ពិភពថ្មីនៃមិត្តភាពប្រកបដោយសក្តានុពល។ ប៉ុន្តែក៏តម្រូវឱ្យយើងមានការប្រុងប្រយ័ត្នចំពោះការប្រថុយប្រថានផ្សេងៗផងដែរ។ **ខាន់ ភីរម្យ**

# កិច្ចប្រជុំក្រុម ជី ២០ ដោះស្រាយបញ្ហាស្មុគស្មាញសេដ្ឋកិច្ចសកល

**ជាត សំភី**

ក្រុមប្រទេស **G 20 (The Group of Twenty, G -20)** រួមមានរដ្ឋមន្ត្រីហិរញ្ញវិត្ថុនៃប្រទេសអភិវឌ្ឍន៍ និងអភិបាលធនាគារកណ្តាលធ្វើការជួបជុំគ្នា។ ក្រុមប្រទេស **G 20** ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៩ ដើម្បីនាំមកនូវការធ្វើឧស្សាហកម្មដែលមានសារៈសំខាន់ជាប្រព័ន្ធ និងសេដ្ឋកិច្ចមានការអភិវឌ្ឍន៍រួមជាមួយគ្នាដោយពិភាក្សាលើបញ្ហាជាគន្លឹះៗនៅក្នុងសេដ្ឋកិច្ចពិភពលោក។

កិច្ចប្រជុំបើកដំបូងនៃក្រុមG ២០ ធ្វើឡើងនៅទីក្រុងប៊ែរឡាំង ប្រទេសអាឡឺម៉ង់ នៅថ្ងៃទី១៥-១៦ ឆ្នាំ១៩៩៩ ដែល ដឹកនាំការប្រជុំដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាឡឺម៉ង់ និងកាណាដា និងធ្វើឡើងរៀងរាល់ឆ្នាំជាបន្តបន្ទាប់។





## សមាជិក ជី ២០

កិច្ចប្រជុំជី ២០ មានការចូលរួមពីរដ្ឋមន្ត្រីហិរញ្ញវត្ថុ និង ទេសាភិបាលធនាគារកណ្តាលនៃ១៩ ប្រទេស: ទី១ អាហ្សង់ទីន ទី២ អូស្ត្រាលី ទី៣ ប្រេស៊ីល ទី៤ កាណាដា ទី៥ ចិន ទី៦ បារាំង ទី៧ អាឡឺម៉ង់ ទី៨ ឥណ្ឌា ទី៩ ឥណ្ឌូនេស៊ី ទី១០ អ៊ីតាលី ទី១១ ជប៉ុន ទី១២ ម៉ិកស៊ិក ទី១៣ រុស្ស៊ី ទី១៤ អារ៉ាប៊ី សាអ៊ូឌីត ទី១៥ អាហ្វ្រិកខាងត្បូង ទី១៦ កូរ៉េខាងត្បូង ទី១៧ ទួគី ទី១៨ អង់គ្លេស ទី១៩ សហរដ្ឋអាមេរិក រួម និងសហភាពអឺរ៉ុប ដែលតំណាងដោយប្រធាន និងទេសាភិបាលធនាគារកណ្តាលសហភាពអឺរ៉ុប ដែលជាសមាជិក ទី២០ របស់ក្រុម ជី ២០។

ប្រទេសសមាជិកតំណាងឱ្យ៨០ភាគរយ នៃពាណិជ្ជកម្មពិភពលោក និង៩០% នៃផលិតផលពិភពលោកសរុប និងពីរភាគបីនៃប្រជាជនពិភពលោក។

ក្រុមប្រទេស**G20** ធ្វើកិច្ចប្រជុំយ៉ាងមានសំខាន់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចអន្តរជាតិ តាមរយៈការលើកកម្ពស់ការពិភាក្សាបើកចំហ ហើយប្រកបដោយការស្ថាបនារវាងប្រទេស ដែលមានទីផ្សារ និងឧស្សាហកម្មរីកចម្រើនលើបញ្ហាគន្លឹះដែលទាក់ទងទៅនឹងស្ថិរភាពសេដ្ឋកិច្ចពិភពលោក។

ក្រុមប្រទេស **G20** ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទាំងវិបត្តិហិរញ្ញវត្ថុនៅចុងទសវត្សរ៍ឆ្នាំ១៩៩០ និងការទទួលស្គាល់នូវការរីកចម្រើនរបស់ប្រទេសនានា ដែលមានទីផ្សារកំពុងរីកចម្រើនជាគន្លឹះ។ ពួកគេរួមបញ្ចូលទាំងការពិភាក្សាលើបញ្ហាស្មុលនៃសេដ្ឋកិច្ចពិភពលោក និងអភិបាលកិច្ច។ កិច្ចប្រជុំ **G20** បានរីកចម្រើនបន្ទាប់ពីវិបត្តិនៅឆ្នាំ១៩៩៩ ដែលបានបង្កើតកិច្ចព្រមព្រៀងអំពីគោលនយោបាយ ដែលកាត់បន្ថយលើការរំលោភបំពានប្រព័ន្ធហិរញ្ញវត្ថុដែលទាក់ទងជាមួយវិបត្តិហិរញ្ញ-វត្ថុ និងការប្រយុទ្ធនឹងភេរវកម្មហិរញ្ញវត្ថុ។

ក្រុមប្រទេស **G20** ក៏មានគោលបំណងគាំទ្រការប្រកាន់យកស្តង់ដារ ដែលទទួលស្គាល់ជាអន្តរជាតិ តាមរយៈគំរូដែលដៅដោយសមាជិករបស់ខ្លួនក្នុងតំបន់រួមមានតម្លាភាពនៃនយោបាយហិរញ្ញវត្ថុ និងការប្រយុទ្ធប្រឆាំងនឹងក្រដាសប្រាក់ក្លែងក្លាយ និងហិរញ្ញវត្ថុរបស់ភេរវកម្ម។





Photos : DR

នៅឆ្នាំ២០០៤ ក្រុមប្រទេស **G20** បានសន្យាធ្វើឱ្យមានស្តង់ដារកាន់តែខ្ពស់ឡើងជាថ្មីនូវតម្លាភាព និងផ្លាស់ប្តូរព័ត៌មានអំពីតារាំងពន្ធគយ។ នេះមានគោលដៅដើម្បីប្រយុទ្ធប្រឆាំងនឹងការរំលោភបំពាននៃប្រព័ន្ធហិរញ្ញវត្ថុ និងសកម្មភាពខុសច្បាប់រួមបញ្ចូលទាំងសកម្មភាពគេចពន្ធ។

ក្រុម **G20** មានគោលដៅដើម្បីអភិវឌ្ឍទស្សនទានរួមក្នុងចំណោមសមាជិកលើបញ្ហាដែលទាក់-ទងទៅនឹងការអភិវឌ្ឍកាន់តែឆ្ងាយទៅលើប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក។

សកម្មភាពសម្រេចចិត្ត និងព្រមព្រៀងគ្នារបស់ប្រទេស **G20** ជាមួយនិងសមាជិកភាពដែលមានការថ្លឹងថ្លែងនៃប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍបានជួយពិភពលោកដោះស្រាយយ៉ាងមានប្រសិទ្ធភាពជាមួយនិងវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រុមប្រទេស**G20** បំពេញរួចហើយនូវលទ្ធផលជាក់ស្តែងមានសារៈសំខាន់ជាច្រើន។

ក្រុមប្រទេស **G20** ធ្វើឱ្យមាននូវការរីកចម្រើនយ៉ាងសម្បើមផងដែរ នៅក្នុងការសម្របសម្រួលនយោបាយដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការម៉ាក្រូសេដ្ឋកិច្ចនៅក្នុងចំណោមសមាជិក **G20** និងដើម្បីបន្ថយផលប៉ះពាល់នៃវិបត្តិ។ ចុងក្រោយ ប្រទេស **G20** បានធ្វើឱ្យអភិបាលកិច្ចពិភពលោកល្អប្រសើរឡើង និងធ្វើឱ្យរីកចម្រើននូវតួនាទី និងតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍជាពិសេតាមរយៈកំណែទម្រង់អភិបាលកិច្ចរបស់មូលនិធិរូបិយវត្ថុអន្តរ-ជាតិ **(IMF)** និងធនាគារពិភពលោក។



Photo : B.Ponnarithy

# សិល្បៈធ្វើក្រចកកំពុងពេញនិយម

**ខាន់ ភីរម្យ**

ការលាប និងគូសក្រចកដើម្បីតុបតែងលំអរាងកាយ គឺត្រូវបានយុវនារីសម័យថ្មីមួយចំនួន ចាត់ទុកថា ជាសិល្បៈមួយបែបដើម្បីលំអជីវិតរបស់ពួកគេផងដែរ ។

យុវនារីជា សុវណ្ណាលិ អាយុ ២៣ឆ្នាំ ប្រជាពលរដ្ឋនៅទួលសង្កែ និយាយថា សព្វថ្ងៃ នេះការតុបតែងខ្លួន ក៏ត្រូវបានគេចាត់ទុកថា ជាសិល្បៈ និងជាមុខវិជ្ជាមួយ ដែលពេញនិយមផងដែរ ជាពិសេសសម្រាប់នារីទាន់សម័យ ។ ជា សុវណ្ណលី ជាសិស្សកំពុងតែរៀនមុខជំនាញកែសម្ផស្សនៅហាងតុបតែងខ្លួនមួយ ។ កញ្ញាអះអាងថា ការលាបក្រចក គឺជាសិល្បៈនៃការតុបតែងខ្លួនមួយបែបហើយបើចង់ចេះជំនាញនេះក៏មិនមែនជាការងាយដែរគឺត្រូវមានការសិក្សាដោយសំភី ។ កញ្ញាបានបញ្ជាក់ដែរថា : "នារីៗគេរៀនធ្វើក្រចកដៃ ដូចជាបុរសៗ គាត់រៀនប្រកបរបរជួសជុលម៉ូតូដូច្នេះដែរ" ។

លោកស្រីសុខ រស្មី ដែលជាម្ចាស់ហាងកែ សម្ផស្ស សុខ រស្មី នៅផ្សារឃ្លាំង រំសេវ រាជធានីភ្នំពេញ បានឱ្យដឹងថា លាបក្រចក គឺជាជំនាញ ដែលគេត្រូវរៀន យ៉ាងហោចណាស់ក៏ ១ខែ កន្លះដែរ ។

បើតាមការអះអាងរបស់លោកស្រីសុខ រស្មី ដើម្បីចេះលាបក្រចកមួយឱ្យស្អាត គេចាំបាច់ត្រូវតែរៀន តាំងពីកាត់មើលសាច់ក្រចក និងចេះជ្រើសរើសនូវពណ៌ផងដែរ ហើយនៅក្នុងពេលបច្ចុប្បន្ននេះ ចំនុចដែលកំពុងតែពេញនិយមនោះ គឺការគូសក្រចកដែលជាការលំបាកមួយ ។

លោកស្រីបញ្ជាក់ថា: "អ្នកដែលចេះគូរក្រចក ទាល់តែឧស្សាហ៍អំណត់ហើយឆ្លាតវៃនៅក្នុងការចងចាំ ។ គូសនៅលើក្រចកមិនធំងាយស្រួលដូចគូសនៅលើក្រដាសនោះទេ" ។លោកស្រីបានបន្តថាក្រៅពីរៀនជាមួយនិងគ្រូហើយ អ្នកដែលអាចគូសបានលុះត្រាតែឧស្សាហ៍ និងស្រាវជ្រាវដើម្បីរត់ឱ្យទាន់ទីផ្សារ ។តួយ៉ាងយើងចេះគូសតែផ្កាផ្កាយ ឬសត្វ ចុះបើភ្ញៀវចង់ឱ្យគូសរូបព្រះច័ន្ទ តើយើងត្រូវធ្វើម៉េច?

លោកស្រីក៏បានឱ្យដឹងថាសព្វថ្ងៃនេះបើចេះគូសក្រចក លាបក្រចក តែ១មុខនោះគេក៏អាចរកចំណូលចិញ្ចឹមខ្លួនបានស្រួល ។ ចំនាយពេលប្រមាណកន្លះម៉ោងជាមួយនិងអតិថិជនម្នាក់ គេអាចរកបានយ៉ាងហោចក៏ ២ដុល្លារដែរ បើគេត្រូវការលាបទាំងក្រចកជើង និងក្រចកដៃ ។ លោកស្រីបានឱ្យដឹងទៀតថាក្រៅពីការលាប ឬគូសក្រចក វិជ្ជាកែសម្រស់ នៅមានច្រើនទៀត ដូចជា ការធ្វើសក់ផាត់មុខ និងម៉ាស្សា-ល- ។

## ខ្ញុំ និងជីតារបស់ខ្ញុំ



ខ្ញុំ និងជីតារបស់ខ្ញុំ ជារឿងរៀបរាប់អំពីអនុស្សាវរីយ៍របស់អ្នកស្រី ម៉ាហ្គេរីតា ឌែលបាល់ហ្សូ **(Margherita Del Balzo)** ដែលជាអ្នកគូរគំនូរជនជាតិអ៊ីតាលីដ៏ល្បីល្បាញកាលវ័យកុមារ ។ពីមួយទំព័រទៅមួយទំព័រទៀត អនុស្សាវរីយ៍ដ៏ពិរោះរបស់ចៅស្រី និងជីតាលេចត្រដែតនៅក្រោមក្រសែភ្នែករបស់អ្នកអានតូចៗ នឹងជក់អារម្មណ៍ ។

ជាមួយនិងអត្ថបទខ្លីៗ ច្បាស់ៗ ស្រួលអាន ងាយយល់ ដោយប្រើភាសាសាមញ្ញ អមដោយរូបគំនូរ យ៉ាងប្រណីត កុមារតូចៗអាចស្វែងយល់អំពីទំនាក់ទំនងរវាងកុមារ និងមនុស្សធំតាមរយៈសកម្មភាពជាប្រចាំថ្ងៃ ការយកចិត្តទុកដាក់នឹងគ្នា ។ រឿងនេះមានបង្កប់នូវចំនុចប្លែកៗតែពីរនាក់ជីតា និងចៅ ដោយមិនឱ្យគេដឹង និងការធ្វើដំណើរកំសាន្តនៅទី កន្លែងផ្សេងៗ...

រឿននេះបាននិពន្ធ និងគូរគំនូរដោយអ្នកស្រី ម៉ាហ្គេរីតា ឌែលបាល់ហ្សូ ។ រឿងនេះបោះពុម្ពជាភាសាខ្មែរឆ្នាំ២០១០ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយពហុ ។ រឿងនេះមានចំនួន ៤៥ទំព័រ និងមានតម្លៃ ៨០០០៛ ។

## យុវអម្ចាស់ក្សត្រី



សារ៉ា គ្រីវ ធំធាត់នៅប្រទេសឥណ្ឌា ជាមួយឪពុករបស់នាង លោកអនុសេនីយ៍ឯករ៉ាល់ហ្វ គ្រីវ ជាអ្នកមានជនជាតិអង់គ្លេស ។ លោកគ្រីវនាំកូនស្រីមករៀននៅប្រទេសអង់គ្លេស ពេលនាងអាយុ៧ឆ្នាំ ។ នៅទីនោះសារ៉ា ត្រូវគេចាត់ទុកដូចជាព្រះអម្ចាស់ក្សត្រីព្រោះឪពុកនាងបញ្ជូនអ្វីៗឱ្យឥតខ្វះ ។

ប៉ុន្តែនៅអាយុ១១ឆ្នាំ ឪពុកនាងស្លាប់ដោយ មិនមានបន្សល់ទ្រព្យសម្បត្តិអ្វីសោះឱ្យនាង ។ អំណើះតទៅ សារ៉ា ត្រូវបម្រើសាលាទាំងមូល ។ នាងស្គាល់ការលំបាកវេទនា និងអត់ឃ្លានសព្វបែបយ៉ាង ។

ទោះបីជាយុវអម្ចាស់ក្សត្រី ជាអក្សរសិល្ប៍ក្លាសិកអង់គ្លេសដែលលើកសរសើរតួអង្គឯកក៏ដោយ ក៏រឿងនេះរួមចំណែកបកស្រាយពីសង្គមអ្នកមាន និងអ្នកក្រភាពលោភលន់ឥតព្រំដែនរបស់មនុស្សមួយក្រុម និងការតស៊ូរៀនរស់តែម្នាក់ឯងរបស់កុមារទុរគត នាដើមសតវត្សទី២០ ។

រឿននេះត្រូវបាននិពន្ធដោយអ្នកស្រីប្រ្ហង់ ហ្វូដសុន ប៊ីណេត បកប្រែជាភាសាខ្មែរដោយលោកចន សំជីន ហើយបោះពុម្ពដោយគ្រឹះស្ថានបោះពុម្ពផ្សាយយុវវ័យ ។

**ហ្សូត សុជាតា**

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ



## ខែកុម្ភៈ ២០១១ អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ ដោយបូជាចារ្យអ៊ុន សួន

**អាទិត្យទី៥ ថ្ងៃទី០៦ កុម្ភៈ ឆ្នាំ២០១១ ដំណឹងល្អ** *(ម៉ាថាយ ៥:១៣-១៦)*

ព្រះយេស៊ូមានព្រះបន្ទូលមកកាន់សាវ័ក និងគ្រីស្តបរិស័ទទាំងអស់ ដើម្បីពន្យល់អំពីមុខងាររបស់គេក្នុងសង្គមមនុស្ស។ អំបិលធ្វើឱ្យម្ហូបមានឱជារស និងថែរក្សាមិនឱ្យម្ហូបអាហារខូច។ រីឯពន្លឺវិញបំភ្លឺចែងចាំងគ្រប់ទីកន្លែង។ ថ្ងៃនេះ ព្រះយេស៊ូបង្រៀនសាវ័ក និងគ្រីស្តបរិស័ទឱ្យមានគុណសម្បត្តិដូចអំបិល និងពន្លឺ។ ដើម្បីបង្ហាញខ្លួន និងណែនាំជីវិតរបស់យើង ជាសាក្សីអំពីព្រះអង្គ។ គ្រីស្តបរិស័ទត្រូវធ្វើកិច្ចការដោយមានជំនឿយ៉ាងមុតមាំ មានការអត់ធ្មត់ សុភាពរៀបសា និងមិនអួតបំប៉ោង ។ល។ យើងជាឧបករណ៍មួយដ៏តូចតាចតែល្អដើម្បីជួយមនុស្សលោក ឧ.តាមសន្ត: ឬសន្តី (អ្នកម្តាយតេរេសានៅទីក្រុងកាល់កុលតា នៃប្រទេសឥណ្ឌា)។ គ្រប់កិច្ចការដែលធ្វើដោយជំនឿពិតប្រាកដ ដូចជាអំបិល និងពន្លឺ សម្រាប់មនុស្សទាំងអស់ឃើញកិច្ចការរបស់អ្នក និងមានការកោតសរសើរព្រះបិតារបស់អ្នកដែលគង់នៅឋានបរមសុខ។

**អាទិត្យទី៦ ថ្ងៃទី១៣ កុម្ភៈ ឆ្នាំ២០១១ ដំណឹងល្អ** *(ម៉ាថាយ ៥:១៧-៣៧)*

ព្រះបន្ទូលដំណឹងល្អថ្ងៃនេះ ព្រះយេស៊ូបង្រៀនអំពីធម្មវិន័យនៃសម្ពន្ធមេត្រីថ្មី។ ព្រះយេស៊ូធ្វើឱ្យការប្រៀនប្រដៅរបស់លោកម៉ូសេ និងអស់លោកព្យាការីពីដើមឱ្យបានពេញលក្ខណ:។ កាលពីដើមក៏ដូចសព្វថ្ងៃនេះ អ្នកកាន់សាសនាជាច្រើនធ្លាប់ធ្វើបុណ្យធ្វើទាន និងកាន់វិន័យយ៉ាងហ្មត់ចត់ដើម្បីឱ្យបានបុណ្យ។ ព្រះយេស៊ូបង្រៀនយើងឱ្យដឹងថា បុណ្យ ឬបាបអាស្រ័យទៅលើចិត្តគំនិតល្អ ឬអាក្រក់របស់យើង។ ព្រះអង្គឱ្យយើងស្រលាញ់ព្រះជាម្ចាស់ និងស្រលាញ់បងប្អូនហើយចិត្តស្មោះ។ ធម្មវិន័យគ្រាន់តែជាគោល សម្រាប់បង្ហាញផ្លូវយើងឱ្យដើរតាម។ ព្រះយេស៊ូ សូមឱ្យយើងជៀសវាងពីការប្រព្រឹត្តអំពើទុចរិតទាំងឡាយការប្រហារជីវិតមនុស្ស ប្រព្រឹត្តិអំពើផិតក្បត់ និងអំពើពាល-ល-។ ព្រះអង្គឱ្យយើងគោរពបងប្អូន ទាំងអស់ក្នុងឋានៈជាបុត្រធីតា ព្រះជាម្ចាស់។ ចូរបងប្អូនរិះគិត តើខ្ញុំត្រូវរស់នៅយ៉ាងណាដើម្បីឱ្យបានស្របតាមព្រះបន្ទូលរបស់ព្រះយេស៊ូ?

**អាទិត្យទី៧ ថ្ងៃទី២០ កុម្ភៈ ឆ្នាំ២០១១ ដំណឹងល្អ** *(ម៉ាថាយ ៥:៣៨-៤៨)*

អត្ថបទគម្ពីនេះ ព្រះយេស៊ូបានយកសេចក្តីស្រលាញ់ធ្វើជាគោល។ សេចក្តីស្រលាញ់ជាកំពូលនៃការប្រៀនប្រដៅរបស់ព្រះយេស៊ូ។ មនុស្សយើងពិតជាពិបាកនឹងអត់ទោសឱ្យអស់អ្នកដែលបានធ្វើបាបខ្លួនណាស់ ឧទាហរណ៍ ខ្មែរក្រហមដែលបានសម្លាប់ជនរួមជាតិឯងយ៉ាងងងឹតងងល់។ តែព្រះយេស៊ូបានធ្វើជាគំរូឱ្យយើងប្រតិបត្តិតាម គឺព្រះអង្គបានអត់ទោសឱ្យអ្នកដែលបានឆ្កាងព្រះអង្គ។ ប្រសិនបើយើងយកតម្រាប់តាមព្រះអង្គ គឺគ្មានចិត្តគុំគួន និងចិត្តសងសឹកព្រមទាំងមានចិត្តអត់ទោសឱ្យគេដែរ។ ព្រះយេស៊ូសុំឱ្យយើងស្រលាញ់ខ្មាំងសត្រូវធ្វើអំពើល្អ និងឱ្យយើងអធិដ្ឋានអង្វរព្រះជាម្ចាស់ចំពោះអស់អ្នកដែលបានធ្វើបាបខ្លួនទៀតផង។ សេចក្តីស្រលាញ់របស់ព្រះយេស៊ូ គឺជាមាគ៌ាដើម្បីឱ្យមនុស្សអាក្រក់ ឬខ្មាំងសត្រូវកែប្រែចិត្តគំនិតដើរទៅរកផ្លូវល្អ។ ចូរបងប្អូនទឹកដល់វិន័យរបស់ព្រះយេស៊ូ: "ខ្ញុំប្រទានក្រឹត្យវិន័យថ្មីឱ្យអ្នករាល់គ្នា គឺអ្នករាល់គ្នាត្រូវស្រលាញ់គ្នា ទៅវិញទៅមកដូចខ្ញុំបានស្រលាញ់អ្នករាល់គ្នាដែរ"។

**អាទិត្យទី៨ ថ្ងៃទី២៧ កុម្ភៈ ឆ្នាំ២០១១ ដំណឹងល្អ** *(ម៉ាថាយ ៦:២៤-៣៤)*

ព្រះអង្គប្រៀនប្រដៅសាវ័កឱ្យបម្រើព្រះជាម្ចាស់តែមួយគត់។ សូមយើងយកសេចក្តីទុក្ខព្រួយទាំងប៉ុន្មានថ្វាយទៅព្រះអង្គ។ សេចក្តីស្រលាញ់របស់មនុស្សយើង ទោះជាមានទំហំធំប៉ុណ្ណាក៏ដោយ ក៏នៅមានកំណត់ព្រំដែន។តែព្រះជាម្ចាស់វិញ ព្រះអង្គមានសេចក្តីស្រលាញ់យ៉ាងធំធេង គ្មានព្រំដែនទេ ព្រោះព្រះអង្គជាសេចក្តីស្រឡាញ់។ ទោះបីជាព្រះជាម្ចាស់ល្អយ៉ាងណាក៏ដោយ ក៏មានមនុស្សជាច្រើនមិនទុកចិត្តលើព្រះអង្គទេ បែរជាទៅរកទីពឹងនូវវត្ថុស័ក្តិសិទ្ធិផ្សេងៗទៀត ដែលមារនាំការល្បួងដើម្បីបញ្ឆោតមនុស្សឱ្យទៅបម្រើមារ។ សម័យនេះសម្តេចប៉ាបបានជួយយើងចាប់អារម្មណ៍វិទ្យាសាស្ត្រទំនើបបច្ចុប្បន្ន នាំឱ្យមនុស្សឃ្លាតឆ្ងាយពីព្រះជាម្ចាស់។ ចូរយើងប្រុងប្រយ័ត្ន កុំបណ្តោយឱ្យខ្លួនតាមសម្បត្តិលោកីយ៍ ប៉ុន្តែផ្ទុយទៅវិញ ព្រះយេស៊ូនាំយើងឱ្យរកសម្បត្តិសួគ៌ គឺឱ្យជឿសង្ឃឹម និងស្រឡាញ់ព្រះអង្គ។ សម្បត្តិសួគ៌ប្រសើរ ជាងសម្បត្តិលោកិយ៍។

## កំណាព្យ

### បីជិត ប្អូនឆ្ងាយ (បទពាក្យ៧)

១. បីជិតប្អូនឆ្ងាយបរិយាយប្រាប់ ពាក្យពេចន៍សារស័ព្ទចាប់សេចក្តី
សូមប្អូនយល់ដឹងនឹងអត្ថន័យ ប្អូនយុវវ័យស្រីប្រុសផង។

២. បីជិតគិតគួរការសិក្សា ទីមួយនេះណាជាចម្បង
ទីពីរកូនល្អតាមគន្លង គ្រាប់តាមបំណងឪពុកម្តាយ។

៣. ទីបីពិសេសម្ល៉េះទេណា ពលរដ្ឋអស្ចារ្យទាំងចិត្តកាយ
ចរិយាសម្បត្តិស្អាត់ជិតឆ្ងាយ កិត្តិនាមសុសសាយពេញប្រទេស។

៤. ប្អូនឆ្ងាយគឺអ្វីខ្លីសោតា ប្រឹងប្រាប់វាចាកុំប្រហែស
ទីមួយព្រួយគិតពិតដូច្នេះ ឋានសាករលេះបេះបាត់បង់។

៥. នោះគឺថ្នាំញៀនព្រានតរក សាកល្បងចង់ភ្លក្សព្រោះចំណង់
ញៀនហើយគ្មានឡើយកាយផូរផង់ ជីវិតរហង់បង់រុះរោយ។

៦. ទីពីរល្បែងស្រីវ័យសិក្សា បង្កើតស្នេហាតាមបណ្តោយ
មិនគិតថ្ងៃមុខទុក្ខថ្ងៃក្រោយ ស្មានតែស្នេហ៍ហើយត្រើយមង្គល។

៧. ទីបីសុរាស្រាស្រវឹង ផឹកច្រើនមិននឹងរឹងអំពល់
ឃើញគេហាក់ដូចតូចសោតសល់ អួតអាងមិនខ្វល់អល់អែកអឺ។

៨. ចំណែកទីប្អូនស្ងួនអើយចាំ ល្បែងបៀចំណាំផ្តាំប្រុសស្រី
មានស៊ីមានសងម្តងម្កាលក្តី កុំបៀតបៀនអីភ័យអន្តរាយ។

៩. ទាំងប្អូនមុខនេះរិះរកគិត តែឋាននៃបនិត្យពិតសោកស្តាយ
កុំយកដាក់ខ្លួនធ្លួនឆោមឆាយ ពាក្យថាប្អូនឆ្ងាយអបាយមុខ។

១០. ទទួលបីជិតពិតត្រឹមត្រូវ ជាផលផ្តល់នូវផ្លូវក្តីសុខ
នាំមកកិត្តិយសខ្ពស់ម៉ែពុក តទៅថ្ងៃមុខសុខមង្គល។

**និពន្ធដោយ:**
**លោកស្រី ខុង ណារី**
**ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១**

# ពិធីសម្ពោធព្រះវិហារនិងសមិទ្ធផលនានានៅគិរីវង្ស ថ្ងៃទី៣០ មករា ឆ្នាំ២០១១

លី សុវណ្ណា

















## “ជៀសពីគ្រឿងញៀន ដើម្បីការពារជីវិតអ្នក”

# លេខទូរស័ព្ទដែលត្រូវហៅ បន្ទាន់

***ប៉ូលីស :**

១១៧

-ប៉ូលីសចរាចរណ៍ ០១២ ៨៩៦ ៦២៨ ។

***រថយន្តសង្គ្រោះបន្ទាន់ :**

១១៩ / ០២៣ ៧២៣ ៨៤០ ។

-ភ្នំពេញ ០២៣ ៧២៤ ៨៩១ ។ -សៀមរាប ០៦៣ ៧៦១ ១១៩ ។

***ក្រុមពន្លត់អគ្គីភ័យ :**

១១៨ / ០២៣ ៧២៣ ៥៥៥ ។

***មណ្ឌលកែប្រែអ្នកញៀនគ្រឿងញៀន :**

០១២ ៨១២ ១១៧ / ០១៥ ៨៩៣ ៩៩៩ ។

---

# វិទ្យុវ៉េរីតាស់អាស៊ី (RVA)

**ផ្នែកភាសាខ្មែរផ្សាយរយៈពេល ៥៧នាទី ជារៀងរាល់ថ្ងៃតាមរយៈ រលកធាតុអាកាសខ្លី (Short Wave = sw) គឺ :**

-ពេលព្រឹក ពីម៉ោង ៨:៣០នាទី ដល់ម៉ោង ៨:៥៧នាទី ផ្សាយក្នុងរលកធាតុអាកាស ១៥២៨០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ១៩,៦៣ ម៉ែត្រ។

-ពេលរសៀល ពីម៉ោង ៥:០០នាទី ដល់ម៉ោង ៥:៣០នាទី ផ្សាយក្នុងរលកធាតុអាកាស ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

ស្ដាប់វិទ្យុវ៉េរីតាស់ អាស៊ី (RVA)

លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើន ទាក់ទងនឹងជីវិតរស់នៅប្រចាំថ្ងៃ និងសង្គម និងព័ត៌មាននានាពីព្រះសហគមន៍កាតូលិកនៅកម្ពុជា។


***ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក***

***មានផលិតជាស៊ីឌី និងវីស៊ីឌីចម្រៀងអំពីព្រះសហគមន៍កាតូលិក និងការលើកតម្កើងព្រះជាម្ចាស់។ ហើយថ្មីៗនេះ យើងខ្ញុំក៏មានចេញលក់នូវស៊ីឌីចម្រៀងថ្មី***

***VCD Vol.01***

***ដូច្នេះបើបងប្អូនប្រិយមិត្តចាប់អារម្មណ៍***

***សូមអញ្ជើញទាក់ទងមកលេខទូរស័ព្ទ ០៩៩ ៩៩៩ ៨៦៥។ សូមអរគុណ !***


# ការងារប្រចាំខែ

- ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១១ : សម្ពោធព្រះវិហារព្រះត្រៃឯកនៅខេត្តតាកែវ ដែលជាអំណោយរបស់លោកសុខកុមារ អូលីវីយេ ជ្មីតអីស្លែរ។
- ថ្ងៃទី០២ ខែកុម្ភៈ : ក្រុមវ៉ាំងសង់ ឌឺ ប៉ូលបានធ្វើការចែកកង់ ២០គ្រឿង ដល់ក្មេងៗក្រីក្រ ដែលកំពុងសិក្សា ដោយពួកគេគ្មានមធ្យោបាយធ្វើដំណើរទៅសាលានៅព្រះសហគមន៍កាតូលិកអ្នកលឿង។
- ថ្ងៃទី៥-៦ ខែកុម្ភៈ : ក្រុមអេម៉ាណូអែលឆ្នាំទី១ និងឆ្នាំទី២ ធ្វើការរិះគិតអំពីការត្រាស់ហៅ នៅក្រោមប្រធានបទ “ព្រះបន្ទូល” នៅមុនបូស្ដិ៍ទឹកថ្លាស្រី រាជធានីភ្នំពេញ។
- ថ្ងៃទី១១-១៨ ខែកុម្ភៈ : នៅព្រះសហគមន៍សៀមរាប ក្រុមយុវជនតៃវ៉ាន ១៦នាក់ ចុះសួរសុខទុក្ខជនក្រីក្រ និងជួយជួសជុលផ្ទះឱ្យអ្នកក្រីក្រ។ មានកម្មវិធីបបរពិសេសសម្រាប់ក្មេងៗ និងលេងល្បែងជាមួយយុវជន និងក្មេងៗ។
- ថ្ងៃទី១៧-២៧ ខែកុម្ភៈ ឆ្នាំ២០១១ : ក្រុមយុវជន ១៧នាក់ មកពីបារាំងមកកសាងផ្ទះសម្រាប់សិស្សានុសិស្សស្នាក់នៅជាបណ្ដោះអាសន្ននៅព្រះសហគមន៍ក្ដុលលើ ភូមិភាគកាតូលិកកំពង់ចាម។
- ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១ : នៅព្រះសហគមន៍ចំណោម ខេត្តបាត់ដំបង មានរៀបចំកម្មវិធីអរគុណព្រះជាម្ចាស់ដែលបានផ្ដល់ផលផ្លែរយៈពេលមួយ។
- ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១១ : ព្រះវិហារសន្ដយ៉ូសែប មានរៀបចំកម្មវិធីសិក្ខាសាលាប្រចាំខែ សម្រាប់គ្រីស្ដបរិស័ទ នៅមណ្ឌលសកម្មភាពភ្នំពេញដើម្បីរួមគ្នារិះគិតអំពីអត្ថន័យនៃព្រះសហគមន៍កាតូលិក។


## ការិយាល័យព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

អ្នកសម្របសម្រួល : លោកស្រីប្រាម៉ុង វីរជ័យ ។ ប្រធាន : លោកលី សុវណ្ណា ។

Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧